ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍
# ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា
# ប្រចាំឆ្នាំ២០២៣



ស័ក្តិសិទ្ធភាព នវានុវត្តន៍ និងបរិយាបន្ន

# អារម្ភកថា

ស្ថិតក្នុងបរិបទប្រែក្លាយទៅជាសេដ្ឋកិច្ចឌីជីថល ការអភិវឌ្ឍនិងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងនវានុវត្តន៍ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ កាត់បន្ថយភាពក្រីក្រ ក៏ដូចជាគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ច។ នៅប្រទេសកម្ពុជា ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអភិវឌ្ឍជាដំណាក់កាលទៅតាមការអភិវឌ្ឍសេដ្ឋកិច្ចដោយសមិទ្ធផលថ្មីៗជាច្រើនត្រូវបានដាក់ឱ្យដំណើរការ និងធ្វើទំនើបកម្ម ដើម្បីសម្រួលប្រតិបត្តិការទូទាត់រាយ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និន្នាការអភិវឌ្ឍក្នុងតំបន់ និងការផ្លាស់ប្តូរឥរិយាបថរបស់អ្នកប្រើប្រាស់។ ជាក់ស្តែង ប្រព័ន្ធបាគងត្រូវបានដាក់ឱ្យដំណើរការ និងពង្រីកមុខងារជាបន្តបន្ទាប់ដូចជា ការប្តូរប្រាក់ក្នុងគណនីបាគងរវាងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក និងការពិនិត្យមើលព័ត៌មានការចាក់វ៉ាក់សាំងកូវីដ-១៩។ ទន្ទឹមនេះ ការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់កម្ពុជាជាមួយប្រទេសក្នុងតំបន់ និងក្រុមហ៊ុនទូទាត់អន្តរជាតិ បានរួមចំណែកយ៉ាងសំខាន់លើការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ និងការបង្វែរប្រាក់ ជាពិសេសពលករដែលកំពុងបម្រើការនៅក្រៅប្រទេស។ ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធខេមបូឌានស្វ៊ីចដើម្បីជាមធ្យោបាយងាយស្រួលសម្រាប់អតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់អាចធ្វើប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថានតាមរយៈប័ណ្ណឥណពន្ធលើគ្រប់ម៉ាស៊ីនដាក់/ដកប្រាក់ស្វ័យប្រវត្តិ និងម៉ាស៊ីនឆូតកាតរបស់គ្រឹះស្ថានសមាជិក និងជា Local Switch សម្រាប់ប្រទេសកម្ពុជាលើការធ្វើសមាហរណកម្មជាមួយប្រទេសក្នុងតំបន់។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំ និងប្រព័ន្ធទូទាត់សងប្រាក់រួម ក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់សេវាទូទាត់សងប្រាក់ជាឌីជីថល សម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់និងទូទាត់ទិញ-លក់ទំនិញនិងសេវា និងផ្តល់លទ្ធភាពឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដោយធ្វើប្រតិបត្តិការទូទាត់តាមប្រព័ន្ធបាគងបានកាន់តែទូលំទូលាយ និងប្រសើរជាងមុន។

ស្របពេលនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗដូចជា រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បង្កើនការវិនិយោគ និងជំរុញឱ្យមានការប្រកួតប្រជែងផ្តល់សេវាទូទាត់សងប្រាក់ឌីជីថលកាន់តែទូលំទូលាយនៅក្នុងប្រទេស។ ជាមួយនឹងទំហំធំនៃការប្រើប្រាស់ទូរស័ព្ទឆ្លាតវៃ និងការផ្គត់ផ្គង់សេវាអ៊ីនធឺណិតក្នុងតម្លៃសមរម្យ បានធ្វើឱ្យការប្រើប្រាស់សេវាទូទាត់សងប្រាក់ឌីជីថលតាមទូរស័ព្ទចល័តកាន់តែមានប្រជាប្រិយភាព និងក្លាយជាមធ្យោបាយទូទាត់យ៉ាងសំខាន់ជំនួសឱ្យការប្រើប្រាស់សាច់ប្រាក់ ជាពិសេសប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលបានចូលរួមកាត់បន្ថយដុល្លារូបនីយកម្មនៅកម្ពុជា។ នៅក្នុងឆ្នាំ២០២៣ ចំនួនប្រតិបត្តិការ និងទំហំប្រាក់នៃការទូទាត់សងប្រាក់ឌីជីថលបានកើនឡើង ៦០% និង ២៥% រៀងគ្នា ធៀបនឹងឆ្នាំ២០២២ ហើយទំហំប្រាក់ស្មើនឹងប្រមាណ ១៦ ដង នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។

ទន្ទឹមនឹងការដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់ និងនវានុវត្តន៍នៃប្រព័ន្ធទូទាត់សងប្រាក់ ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ការរៀបចំក្របខណ្ឌបទប្បញ្ញត្តិសមស្របសម្រាប់គ្រប់គ្រង និង

ជំរុញការអភិវឌ្ឍក្នុងវិស័យនេះជាកត្តាចាំបាច់ដើម្បីធានាថា ប្រព័ន្ធទូទាត់បានរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ កន្លងមក ធនាគារជាតិនៃកម្ពុជា បានរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រកាសមួយចំនួន និងកំពុងបន្តរៀបចំប្រកាសបន្ថែមទៀតពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ សេវាទូទាត់ ឧបករណ៍ទូទាត់ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព សុវត្ថិភាពប្រព័ន្ធ និងឧបករណ៍ទូទាត់ ព្រមទាំងជំរុញនវានុវត្តន៍ និងការប្រកួតប្រជែងនៃសេវានិងឧបករណ៍ទូទាត់ថ្មីៗក្នុងទីផ្សារ។ ការផ្តល់សេវាហិរញ្ញវត្ថុតាមបែបឌីជីថលតាមរយៈការអភិវឌ្ឍ និងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ បានគាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ របស់រាជរដ្ឋាភិបាលកម្ពុជា។

ជាទីបញ្ចប់ សមិទ្ធផលខាងលើនេះអាចសម្រេចទៅបានក្រោមម្លប់សន្តិភាពពេញលេញ តាមរយៈ "គោលនយោបាយឈ្នះ-ឈ្នះ" ដែលដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ មូលដ្ឋានដ៏រឹងមាំនេះ ផ្តល់នូវកាលានុវត្តភាពដល់ធនាគារជាតិនៃកម្ពុជាអាចអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ដែលមានលក្ខណៈប្រទាក់ក្រឡា និងគ្រប់ជ្រុងជ្រោយ ដែលអាចទាញយកផលប្រយោជន៍ជាអតិបរមាពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលប្រកបដោយបរិយាបន្ន ភាពជឿទុកចិត្ត និងសុវត្ថិភាពខ្ពស់ ហើយដំណាលគ្នានេះ ប្រទេសកម្ពុជាក៏បានលេចធ្លោលើឆាកអន្តរជាតិក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយនវានុវត្តន៍ ស្របតាមមុំទី៥ នៃបញ្ចកោណទី៥ ស្តីពីការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលរាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ បានដាក់ចេញ។ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ដែលតែងតែផ្តល់ការគាំទ្រ និងមន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមគ្នាអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់នៅប្រទេសកម្ពុជាឱ្យមានភាពរីកចម្រើន និងប្រកបដោយនវានុវត្តន៍។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា និងដៃគូអភិវឌ្ឍន៍នានាដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក។

ខ្ញុំមានសេចក្តីជឿជាក់យ៉ាងមុតមាំថា របាយការណ៍ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ប្រចាំឆ្នាំ២០២៣ នេះ នឹងក្លាយជាឯកសារដ៏មានសារៈសំខាន់សម្រាប់សាធារណជនទាំងអស់ សិក្សាស្វែងយល់បន្ថែមពីការងារដែលធនាគារជាតិនៃកម្ពុជាកំពុងអនុវត្ត វឌ្ឍនភាពថ្មីៗ ស្តីពីការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា និងទិសដៅនាពេលអនាគត។

**ទេសាភិបាល**

**ជា សិរី**

# មាតិកា


**អារម្ភកថា** | i

**បញ្ជីក្រាហ្វ និងប្រអប់** | iv

**អក្សរកាត់** | vi

**បរិយាយសង្ខេប** | viii

**ស្ថិតិអំពីស្ថានភាពសេវាទូទាត់សងប្រាក់** | xii

**១ វឌ្ឍនភាពរបស់ប្រព័ន្ធទូទាត់សងប្រាក់** | ១

ការអភិវឌ្ឍចម្បងៗ | ១
គោលនយោបាយគាំទ្រ | ៤
ជំហានបន្ទាប់ | ៩

**២ នវានុវត្តន៍ប្រព័ន្ធបាគង** | ១៣

វឌ្ឍនភាពប្រព័ន្ធបាគង | ១៣
នវានុវត្តន៍ប្រព័ន្ធបាគង | ១៦

**៣ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់** | ២០

ការត្រួតពិនិត្យតាមដានប្រព័ន្ធទូទាត់សងប្រាក់ | ២០
ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ | ២៨
ស្តង់ដារឧបករណ៍ និងបណ្តាញប្រព័ន្ធទូទាត់សងប្រាក់ | ៣០

**៤ ការគ្រប់គ្រងសេវាទូទាត់សងប្រាក់** | ៣៤

ទិដ្ឋភាពទូទៅ និងការវិវត្តន៍ | ៣៤
ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៣៨
ការវិភាគ និងវាយតម្លៃសុខុមាលភាពគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៣៩
ការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៤០

**៥ ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន** | ៤២

កិច្ចសហប្រតិបត្តិការទ្វេភាគី លើគម្រោងផ្ទេរប្រាក់ និងការទូទាត់ឆ្លងដែន | ៤២
ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន | ៤៧

**ឧបសម្ព័ន្ធ** | ៥០

ឧបសម្ព័ន្ធ ១ - ច្បាប់ និងបទប្បញ្ញត្តិ | ៥០
ឧបសម្ព័ន្ធ ២ - បញ្ជីរាយនាមឈ្មោះសមាជិកប្រព័ន្ធបាគង | ៥២
ឧបសម្ព័ន្ធ ៣ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៥៤
ឧបសម្ព័ន្ធ ៤ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក | ៥៩
ឧបសម្ព័ន្ធ ៥ - ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបាគង | ៦១

# បញ្ជីក្រាហ្វ និងប្រអប់

## ក្រាហ្វ

ក្រាហ្វ ១ - រូបិយវត្ថុក្នុងចរាចរ និងទំហំប្រាក់ទូទាត់តាមប្រព័ន្ធឌីជីថលជាប្រាក់រៀល ................. ២
ក្រាហ្វ ២ - ប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណទូទាត់ និងការស្កេន QR Code ............................. ៣
ក្រាហ្វ ៣ - ចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់ជាមួយកម្មវិធីបាគង ........................................ ១៤
ក្រាហ្វ ៤ - ប្រតិបត្តិការធ្វើឡើងតាមរយៈប្រព័ន្ធបាគង ........................................................ ១៥
ក្រាហ្វ ៥ - ទំហំប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិក មុនដាក់ និងបន្ទាប់ពីបានដាក់ដំណើរការជាផ្លូវការប្រព័ន្ធបាគង ............................................................................ ១៥
ក្រាហ្វ ៦ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ............................................................ ២១
ក្រាហ្វ ៧ - បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក .................. ២២
ក្រាហ្វ ៨ - បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធ FAST .................................................................. ២៣
ក្រាហ្វ ៩ - ប្រតិបត្តិការប័ណ្ណឥណពន្ធ តាមប្រព័ន្ធខេមបូឌានស៊ែស្វីច ................................... ២៥
ក្រាហ្វ ១០ - ប្រតិបត្តិការផ្ទេរប្រាក់ តាមប្រព័ន្ធធនាគារអនឡាញ ......................................... ២៦
ក្រាហ្វ ១១ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិក តាមប្រព័ន្ធ RFT ...................................... ២៧
ក្រាហ្វ ១២ - ចំនួន និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ................... ២៨
ក្រាហ្វ ១៣ - ចំនួនភ្នាក់ងារ អតិថិជនចុះឈ្មោះគណនី E-wallet និងអតិថិជន Walk-in របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់ .......... ៣៤
ក្រាហ្វ ១៤ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័ត តាមកាបូបអេឡិចត្រូនិក (Mobile E-wallet) ........................................................................ ៣៥
ក្រាហ្វ ១៥ - សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ ................................ ៣៥
ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការរបស់សេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត ........................................................................................ ៣៦

ក្រាហ្វ ១៧ - ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងប័ណ្ណទូទាត់អន្តរជាតិ) ............... ៣៧
ក្រាហ្វ ១៨ - ចំនួនម៉ាស៊ីន ATM  និងម៉ាស៊ីន POS ............................................................ ៣៧
ក្រាហ្វ ១៩ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR Code ....................... ៣៨
ក្រាហ្វ ២០ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន ............................. ៤៨
ក្រាហ្វ ២១ - ទំហំប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន តាមប្រព័ន្ធ ITRS ............... ៤៩

## ប្រអប់

ប្រអប់ ១ - ការអភិវឌ្ឍគម្រោង Financial Transparency Corridor ......................................... ១១
ប្រអប់ ២ - ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ប្រព័ន្ធបាគង ......... ១៩
ប្រអប់ ៣ - វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០២៣ ...................................................... ៣៣

# អក្សរកាត់

| | | |
|---|---|---|
| ATM | Automated Teller Machine | ម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ |
| BAKONG | BAKONG System | ប្រព័ន្ធបាគង |
| BCM | Business Continuity Management | ការគ្រប់គ្រងផែនការនិរន្តរភាពប្រព័ន្ធ |
| BIN | Bank Identification Number | លេខអត្តសញ្ញាណធនាគារ |
| CBC | Credit Bureau Cambodia | ការិយាល័យឥណទានកម្ពុជា |
| CPSS and IOSCO | Committee on Payment and Settlement Systems and International Organization of Securities Commissions | គណៈកម្មការប្រព័ន្ធទូទាត់ និងផាត់ទាត់និងគណៈកម្មការមូលបត្រអន្តរជាតិ |
| CSS | Cambodian Shared Switch | ប្រព័ន្ធខេមបូឌានស៊ែស្វីច |
| DLT | Distributed Ledger Technology | បច្ចេកវិទ្យាឌីអិលធី |
| ECS | Electronic Clearing System | ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក |
| EMV | Europay, Mastercard, and VISA | ស្តង់ដារអ៊ីអឹមវី |
| FAST | FAST Payment System | ប្រព័ន្ធសេវាទូទាត់រហ័ស |
| FINTECH | Financial Technology | បច្ចេកវិទ្យាហិរញ្ញវត្ថុ |
| FTC | Financial Transparency Corridor | គម្រោងតម្លាភាពហិរញ្ញវត្ថុ |
| ISO | International Organization for Standardization | អង្គការស្តង់ដារអន្តរជាតិ |
| ITRS | International Transactions Reporting System | ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ |
| KHQR Code | Khmer Quick Response Code | ខេអេចឃ្យូអរកូដ |

| | | |
|---|---|---|
| KYC | Know Your Customer | នីតិវិធីស្គាល់អតិថិជន |
| NBC | National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា |
| NCS | National Clearing System | ប្រព័ន្ធជាត់ទាត់ជាតិ |
| OBS | Online Banking System | ប្រព័ន្ធធនាគារអនឡាញ |
| PFMI | Principles for Financial Market-Infrastructures | គោលការណ៍សម្រាប់-ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ |
| POS | Point of Sale | ម៉ាស៊ីនឆូតកាត |
| QPS | QR Code Payment System | ប្រព័ន្ធទូទាត់តាមឃ្យូអរកូត |
| QR Code | Quick Response Code | ឃ្យូអរកូត |
| RETAIL PAY | Retail Pay System | ប្រព័ន្ធរីធែលផេ |
| RFT | Real-Time Fund Transfer System | ប្រព័ន្ធផ្ទេរប្រាក់ភ្លាមៗ |
| SME | Small-Medium Enterprise | សហគ្រាសធុនតូច និងមធ្យម |
| STP | Straight Through Processing | ប្រតិបត្តិការជាលក្ខណៈស្វ័យប្រវត្តិ |
| SWIFT | The Society for Worldwide Interbank Financial Telecommunication | បណ្ដាញទូរគមនាគមន៍ហិរញ្ញវត្ថុនៃធនាគារទូទាំងពិភពលោក |
| UPI | UnionPay International | ក្រុមហ៊ុនទូទាត់អន្តរជាតិយូញៀនផេ |

# បរិយាយសង្ខេប

ប្រព័ន្ធទូទាត់សងប្រាក់បានរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ដើម្បីសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ ការទូទាត់ចំពោះការទិញ-លក់ទំនិញនិងសេវា និងការជួញដូរនៅលើទីផ្សារហិរញ្ញវត្ថុជាដើម។ លើសពីនេះ ប្រព័ន្ធទូទាត់សងប្រាក់ក៏បានរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍសេវា និងឧបករណ៍ទូទាត់សងប្រាក់ប្រកបដោយនវានុវត្តន៍ ដែលមានតម្លៃសមរម្យ និងមានលក្ខណៈទូលំទូលាយ ផ្តល់លទ្ធភាពឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាទូទាត់សងប្រាក់ តាមរយៈសេវាហិរញ្ញវត្ថុឌីជីថល ឬផ្លូវការ សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍប្រព័ន្ធទូទាត់ ធនាគារជាតិនៃកម្ពុជាបានបន្តដាក់ឱ្យប្រើប្រាស់ និងអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួមមាន ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធធនាគារអនឡាញ (OBS) ប្រព័ន្ធបាគង (BAKONG) ប្រព័ន្ធរីថែលផេ (Retail Pay) និងប្រព័ន្ធខេមបូឆានស៊ែស្វីច (CSS) ដើម្បីសម្រួលដល់ប្រតិបត្តិការឆ្លងគ្រឹះស្ថានប្រកបដោយភាពងាយស្រួល សុវត្ថិភាព និងរក្សាប្រក្រតីភាពនៃសកម្មភាពទូទាត់ក្នុងសេដ្ឋកិច្ចកម្ពុជា។

ប្រព័ន្ធផាត់ទាត់ជាតិដែលជាប្រព័ន្ធទូទាត់សំខាន់មានលក្ខណៈជាប្រព័ន្ធ ត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជំនាន់ថ្មី ២.០ និងបានដាក់ដំណើរការដោយរលូនក្នុងប្រតិបត្តិការទូទាត់តាមរយៈមូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក ដើម្បីបង្កើនសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធ និងធានាបានប្រសិទ្ធភាពក្នុងការធ្វើប្រតិបត្តិការបានប្រសើរជាងមុន។ ប្រតិបត្តិការទូទាត់និងផាត់ទាត់មូលប្បទានបត្រ និងបញ្ជាអេឡិចត្រូនិកជាប្រាក់រៀល នៅបន្តកើនឡើងទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ ដោយចំនួនប្រតិបត្តិការកើនឡើងក្នុងអត្រា ១,៥% និង ២៥,៧% រៀងគ្នា និងទំហំប្រាក់កើនឡើងក្នុងអត្រា ១០,៩% និង ៦,៩% រៀងគ្នា ចំណែកឯប្រតិបត្តិការទូទាត់និងផាត់ទាត់មូលប្បទានបត្រ និងបញ្ជាអេឡិចត្រូនិកជាប្រាក់ដុល្លារអាមេរិកមានការថយចុះទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់បើធៀបនឹងឆ្នាំ២០២២។ ទន្ទឹមនេះ ទំហំប្រាក់ប្រតិបត្តិការជាប្រាក់រៀលតាមរយៈប្រព័ន្ធសេវាទូទាត់រហ័សនៅបន្តរក្សាកំណើនក្នុងអត្រា ១៦% និងប្រតិបត្តិការតាមរយៈប្រព័ន្ធធនាគារអនឡាញក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ បើធៀបនឹងឆ្នាំ២០២២។ ដោយឡែក ប្រតិបត្តិការតាមរយៈប្រព័ន្ធខេមបូឆានស៊ែស្វីច និងប្រព័ន្ធរីថែលផេ មាននិន្នាការថយចុះ ស្របពេលទំហំប្រាក់ប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកតាមរយៈប្រព័ន្ធបាគងមានសន្ទុះកើនឡើងក្នុងអត្រាប្រមាណ ២៥៨,៩% និង ១៥៨,៨% រៀងគ្នា បើធៀបនឹងឆ្នាំមុន។

ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោងត្រូវបានអភិវឌ្ឍឡើងដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថាន បង្កើនប្រសិទ្ធភាព ជំរុញបរិយាបន្នហិរញ្ញវត្ថុ និងលើកកម្ពស់ការទូទាត់ជាប្រាក់រៀល។ នៅក្នុងឆ្នាំ២០២៣ នេះ ការប្រើប្រាស់ប្រព័ន្ធបាគងនៅប្រទេសកម្ពុជាមានសន្ទុះកើនឡើងយ៉ាងខ្លាំង ដែលនេះបង្ហាញពីភាពពេញនិយម និងភាពរីកចម្រើននៃការទូទាត់តាមឌីជីថល ជាពិសេសការផ្ទេរប្រាក់ និងទូទាត់តាមយូអរកូត។ ដោយមើលឃើញពីភាពជោគជ័យនេះ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ការទូទាត់ឆ្លងដែន និងបានដាក់ដំណើរការជាផ្លូវការជាមួយប្រទេសក្នុងតំបន់ និងដៃគូសហការ រួមមាន ប្រទេសថៃ ម៉ាឡេស៊ី ឡាវ វៀតណាម ក្រុមហ៊ុនអន្តរជាតិយូញៀនផេ (UnionPay International - UPI) និងកំពុងបន្តអភិវឌ្ឍគម្រោងទូទាត់ឆ្លងដែនជាមួយបណ្តាប្រទេសផ្សេងទៀតដូចជា ប្រទេសចិន ជប៉ុន ឥណ្ឌា សិង្ហបុរី និងក្រុមហ៊ុនអាលីផេ (Alipay)។ ការអភិវឌ្ឍគម្រោងនេះនឹងផ្តល់ជាមធ្យោបាយសម្រួលក្នុងការទូទាត់ឆ្លងដែនដល់អ្នកប្រើប្រាស់ដូចជាភ្ញៀវទេសចរ ពលករ និងអ្នកធុរកិច្ច។ ស្របពេលគ្នានេះដែរ បន្ទាប់ពីដាក់ឱ្យដំណើរការដោយជោគជ័យប្រព័ន្ធបាគងសម្រាប់ប្រព័ន្ធទូទាត់រាយ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ការទូទាត់តម្លៃធំដោយប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី (Distributed Ledger Technology - DLT) ដើម្បីគាំទ្រដល់ប្រតិបត្តិការទូទាត់តម្លៃធំ និងការទូទាត់ឆ្លងដែន ដោយបច្ចុប្បន្នធនាគារជាតិនៃកម្ពុជាកំពុងរៀបចំឯកសារគតិយុត្តស្តីពីវិធាននិងនីតិវិធី ដើម្បីគាំទ្រដំណើរការប្រព័ន្ធនេះ។ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព សុវត្ថិភាព លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ និងផ្តល់ភាពងាយស្រួលដល់អតិថិជនមួយកម្រិតទៀត ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម ដែលតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលបានដាក់ឱ្យដំណើរការកន្លងមកជាច្រកទូទាត់តែមួយដើម្បីសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ឆ្លងគ្រឹះស្ថាន។ ការណ៍នេះបង្ហាញថាការធ្វើបច្ចុប្បន្នកម្ម និងនវានុវត្តន៍ផ្នែកប្រព័ន្ធទូទាត់បានក្លាយជាធាតុសំខាន់ក្នុងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសកម្ពុជា និងបានរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុតាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេវា និងឧបករណ៍ទូទាត់សងប្រាក់ប្រកបដោយនវានុវត្តន៍ មានលក្ខណៈទូលំទូលាយ និងផ្តល់លទ្ធភាពឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាទូទាត់សងប្រាក់តាមរយៈសេវាហិរញ្ញវត្ថុផ្លូវការ សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។

ក្រោយពីសេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញយ៉ាងឆាប់រហ័សបន្ទាប់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដើម្បីជំរុញដល់ពាណិជ្ជកម្ម និងសេវាហិរញ្ញវត្ថុឆ្លងដែន ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរី អភិវឌ្ឍគម្រោង Financial Transparency Corridor (FTC) ក្នុងគោលបំណងបង្កើតហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីសម្រួលដល់ពាណិជ្ជកម្ម និងសេវាហិរញ្ញវត្ថុឆ្លងដែនសម្រាប់សហគ្រាសធុនតូចនិងមធ្យម (SME) រវាងប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា។ គម្រោង FTC នេះ នឹងជួយសម្រួលដល់សហគ្រាសធុនតូចនិងមធ្យម

នៅប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា មានលទ្ធភាពពង្រីកបណ្តាញពាណិជ្ជកម្មឌីជីថលកាន់តែទូលំទូលាយ និងផ្តល់ឱកាសដល់ការភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មកាន់តែប្រសើរក្នុងតំបន់អាស៊ាន និងតំបន់ផ្សេងៗទៀត។

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តដាក់ឱ្យអនុវត្តស្តង់ដារជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់អន្តរប្រតិបត្តិការ និងសុវត្ថិភាពក្នុងការទូទាត់ ជាក់ស្តែងធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ស្តង់ដារឧបករណ៍ និងតាមបណ្តាញទូទាត់សងប្រាក់ រួមមាន ស្តង់ដារឃ្យូអរកូត ស្តង់ដារលេខអត្តសញ្ញាណធនាគារ (BIN) មូលប្បទានបត្រស្តង់ដារ គំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានជាអេឡិចត្រូនិក ដើម្បីសម្រួលដល់ការផាត់ទាត់ និងទូទាត់នៅសភាផាត់ទាត់ជាតិ។ ក្នុងនោះ ធនាគារជាតិនៃកម្ពុជាបានដាក់ដំណើរការស្តង់ដារខេអេចឃ្យូអរកូត (KHQR Code) ដែលអនុញ្ញាតឱ្យអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាមានលទ្ធភាពធ្វើប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់ឆ្លងគ្រឹះស្ថាន។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាបានកំណត់ស្តង់ដារលេខអត្តសញ្ញាណធនាគារលើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក (៩១១៦) និងកំពុងជំរុញគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យប្រើប្រាស់ស្តង់ដារ EMV Chip សម្រាប់ប័ណ្ណទូទាត់។ គោលការណ៍សុវត្ថិភាពនៅលើម៉ាស៊ីនដាក់/ដកប្រាក់ (ATM) និង/ឬ ម៉ាស៊ីនឆូតកាត (POS) ក៏ត្រូវបានដាក់ឱ្យសមាជិកប្រព័ន្ធខេមបូឌានស៊ែស្វីចប្រើប្រាស់ផងដែរ។

ស្របពេលនឹងការដាក់ប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ សេវាទូទាត់សងប្រាក់ឌីជីថលមានការរីកចម្រើនជាលំដាប់នៅក្នុងប្រទេសកម្ពុជា ដោយបានធ្វើការផ្លាស់ប្តូរនូវប្រព័ន្ធធនាគារឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល។ ការកើនឡើងនូវចំនួនគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុបានជំរុញឱ្យមានការប្រកួតប្រជែង និងពង្រីកសេវាទូទាត់ និងផ្ទេរប្រាក់តាមមធ្យោបាយអេឡិចត្រូនិកកាន់តែទូលំទូលាយនៅក្នុងប្រទេស ដូចជា ផ្ទេរប្រាក់ ដាក់/ដកប្រាក់ សេវាទូទាត់វាយ ទូទាត់វិក្កយបត្រ ទូទាត់អនឡាញ ផ្ទេរប្រាក់ឆ្លងដែន និងការទូទាត់តាមគម្រោងទូទាត់អន្តរជាតិ។ សេវាទូទាត់សងប្រាក់ឌីជីថលដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មានការកើនឡើងចំនួនប្រមាណ ៤៧,២% ធៀបនឹងឆ្នាំមុន ជាមួយនឹងទំហំប្រាក់មានចំនួនប្រមាណ ៣០៨ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣។

ដើម្បីធានាបាននិរន្តរភាព និងស្ថិរភាពនៃកិច្ចដំណើរការប្រព័ន្ធ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដោយអនុលោមទៅតាមបទដ្ឋានស្តង់ដារគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់ផ្តោតសំខាន់លើប្រសិទ្ធភាព និងសុវត្ថិភាពនៃប្រតិបត្តិការប្រព័ន្ធទូទាត់ ដោយរួមមានទាំងការតាមដាននិន្នាការនៃប្រតិបត្តិការទូទាត់ និងការគ្រប់គ្រងហានិភ័យ ដូចជា ហានិភ័យសន្ទនីយភាព ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យទូទាត់ និងជាពិសេសហានិភ័យជួលរលំជា

ប្រព័ន្ធ។ ចំណែកឯ ការត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏ត្រូវបានអនុវត្តតាមរយៈការត្រួតពិនិត្យលើឯកសារនិងការត្រួតពិនិត្យដល់ទីកន្លែង ដោយយកចិត្តទុកដាក់លើការអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ជាពិសេសការវាយតម្លៃផ្អែកលើបទប្បញ្ញត្តិប្រុងប្រយ័ត្ន និងច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ដោយសារធនាគារជាតិនៃកម្ពុជាជាបញ្ញត្តិករគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ទើបថ្មីៗនេះ បទប្បញ្ញត្តិគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអនុម័តជាបន្តបន្ទាប់។ នៅក្នុងឆ្នាំ២០២៣ សេចក្តីណែនាំស្តីពី "ការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់កិច្ចសហការផ្ទេរប្រាក់អន្តរជាតិ ក្នុងដំណាក់កាលសាកល្បង" ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីឱ្យការអនុវត្តមានលក្ខណៈស្តង់ដារ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំប្រកាសបន្ថែមទៀត ដែលក្នុងនោះរួមមាន ការកំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការគ្រប់គ្រងគណនីអាណត្តិព្យាបាល ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិការទីផ្សារតេណទានតាមប្រព័ន្ធអេឡិចត្រូនិក។

ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថល ជាការងារអាទិភាពរបស់ធនាគារជាតិនៃកម្ពុជា ដោយសារចំណេះដឹងផ្នែកឌីជីថលជាធាតុសំខាន់មួយក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ និងបរិវត្តកម្មឌីជីថល។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានាដើម្បីអនុវត្តការងារអាទិភាពនេះ ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។ នៅក្នុងឆ្នាំ២០២៣ នេះ ធនាគារជាតិនៃកម្ពុជាបានចុះផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ប្រព័ន្ធបាគងដល់សាធារណជនទូទៅនៅតាមបណ្តាខេត្ត-ក្រុង រួមមាន ខេត្តកំពត ខេត្តកំពង់ធំ និងខេត្តកោះកុង ដែលមានអ្នកចូលរួមជាមន្ត្រីធនាគារជាតិនៃកម្ពុជា មន្ត្រីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សិស្សានុសិស្ស និងប្រជាពលរដ្ឋជាច្រើនរូប។

# ស្ថិតិអំពីស្ថានភាពសេវាទូទាត់សងប្រាក់

## ១. ស្ថិតិទូទៅ

| | ឆ្នាំ២០២២ | ឆ្នាំ២០២៣ |
|---|---|---|
| ចំនួនប្រជាជនសរុប (ខ្ទង់លាន) [១] | ១៦,៨៤ | ១៧,០៩ |
| ផលិតផលក្នុងស្រុកសរុប (ខ្ទង់លានដុល្លារអាមេរិក) [២] | ២៩.៥៩៩ | ៣២.០៦៥ |
| ផលិតផលក្នុងស្រុកសរុប ក្នុងប្រជាជនម្នាក់ (ដុល្លារអាមេរិក) [២] | ១.៧៦៥ | ១.៨៧៦ |

## ២. គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ [២]

| ប្រភេទគ្រឹះស្ថាន | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | និន្នាការ |
|---|---|---|---|
| ធនាគារពាណិជ្ជ | ៥៩ | ៥៨ | (១,៦៩%) |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៥ | ៤ | (២០%) |
| គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៣៥ | ៣៣ | (៥,៧០)% |
| អ្នកដំណើរតតិយភាគី | ៦ | ៦ | - |

## ៣. ឧបករណ៍ទូទាត់សងប្រាក់ [២] (ឯកតាខ្ទង់លាន)

| ប្រភេទឧបករណ៍ | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | និន្នាការ |
|---|---|---|---|
| **៣.១ ប្រភេទឧបករណ៍រូបវន្ត** | | | |
| ប័ណ្ណ Proprietary | ៣,១១ | ៣,២១ | ៣,១៨% |
| ប័ណ្ណ Debit | ២,៣២ | ២,៥១ | ៨,៤០% |
| ប័ណ្ណ Credit | ០,១៦ | ០,២១ | ៣០,៤០% |
| ប័ណ្ណ Prepaid | ៦,៧៣ | ៧,១៣ | ៥,៩០% |
| **៣.២ ប្រភេទឧបករណ៍បែបឌីជីថល** | | | |
| គណនីធនាគារសន្សំ | ១៥,៥ | ១៦,០២ | ៣,៣៥% |
| គណនីកាបូបអេឡិចត្រូនិក | ១៩,៥ | ១៩,៦៦ | ១,១០% |
| គណនីបាគង | ០,៥២ | ០,៦០ | ១៤,៩% |

## ៤. បណ្តាញទូទាត់ [២] (ឯកតាខ្ទង់ពាន់)

| ចំនួនបណ្តាញទូទាត់ | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | និន្នាការ |
|---|---|---|---|
| សាខាធនាគារពាណិជ្ជ | ១,៥០ | ១,៥៤ | ២,៦៧% |
| សាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ០,៦៣ | ០,៦៣ | - |
| ម៉ាស៊ីន ATM | ៤,៣៩ | ៥,៤៤ | ២៣,៩០% |
| ម៉ាស៊ីន POS | ៥៤,០៦ | ៥២,០៦ | (៣,៧០)% |
| ភ្នាក់ងារផ្តល់សេវាទូទាត់ | ៥២,៣ | ៦០,៤៨ | ១៥,៧០% |

[១] ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ
[២] ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥. ប្រតិបត្តិការទូទាត់សងប្រាក់[២] (ឯកតាខ្ទង់លាន)

| | ឆ្នាំ២០២២ | | ឆ្នាំ២០២៣ | | និន្នាការ | |
|---|---|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | រៀល | ដុល្លារអាមេរិក | រៀល | ដុល្លារអាមេរិក |
| **៥.១ មូលប្បទានបត្រ** | | | | | | |
| ចំនួនប្រតិ. | ០,០៣៤ | ១,១១ | ០,០៣៤ | ១,០៤ | ០,៣២% | (៦,១៥)% |
| ទំហំប្រាក់ | ១៩.៨៣១.៣១០ | ៥៣.៨៥៤ | ២២.០០២.៧៥០ | ៤៤.៤៣៣ | ១០,៩៥% | (១៧,៤៩%) |
| **៥.២ បញ្ជាទូទាត់អេឡិចត្រូនិក** | | | | | | |
| ចំនួនប្រតិ. | ០,០២៣ | ០,៦៨ | ០,០២៨ | ០,៦៣ | ២៣,១៩% | (៧,០៦)% |
| ទំហំប្រាក់ | ៤.៥៦១.០១០ | ១២.៣១៩ | ៤.៨៧៦.៩៤០ | ១៣.១១៨ | ៦,៩៣% | ៦,៤៩% |
| **៥.៣ ប័ណ្ណទូទាត់ [៣]** | | | | | | |
| ចំនួនប្រតិ. | - | ១១៩,៧៥ | - | ១៨១,៣៩ | - | ៥១,៤៧% |
| ទំហំប្រាក់ | ២២.៣៦៨.៤៧០ | ១៨.៥១០ | ៥៥.១៤២.៩៨៨ | ១៨.០១០ | ១៤៦,៥២% | (២,៧០)% |
| **៥.៤ កាបូបអេឡិចត្រូនិក** | | | | | | |
| ចំនួនប្រតិ. | ១៩៨,៨ | ២៦៨,៥៧ | ២២៧,៧៥ | ៣៧៣,៥៤ | ១៤,៥៦% | ៣៩,០៨% |
| ទំហំប្រាក់ | ១១៩.៨៩៤.៨៥០ | ៣៤.៣០០ | ១២៧.៣៨៧.៩៦៥ | ៤៣.៩៩៥ | ៦,២៥% | ២៨,២៦% |
| **៥.៥ សេវាធនាគារចល័ត** | | | | | | |
| ចំនួនប្រតិ. | ៣២,៥៦ | ៤៥២,៥៨ | ៨៦,៧៩ | ៦៩២,៦៦ | ១៦៦,៥៧% | ៥៣,០៥% |
| ទំហំប្រាក់ | ៤៣.៦៣៧.៦៨០ | ១៥៣.៨៣០ | ៧៣.១១៤.២៣៤ | ១៦៣.៨៧៨ | ៦៧,៥៥% | ៦,៧៤% |
| **៥.៦ សេវាធនាគារអ៊ីនធឺណិត** | | | | | | |
| ចំនួនប្រតិ. | ០,២៥ | ៣,០៥ | ០,២១ | ៤,៤៩ | (១៥,០៨)% | ៤៧,២៩% |
| ទំហំប្រាក់ | ១១.៣១២.៥៨០ | ១៦.៨៣០ | ៩.២០៦.៧៦២ | ១៥.៨១៦ | (១៨,៦១)% | (៥,៦១)% |
| **៥.៧ ប្រព័ន្ធបាគង** | | | | | | |
| ចំនួនប្រតិ. | ៥,៨៩ | ២០,២៣ | ៦៨,៧៩ | ១៣២,១៤ | ១.០៦៧,៩១% | ៥៥៣,១៩% |
| ទំហំប្រាក់ | ១២.៨១៣.៦៤៧ | ១២.២១១ | ៨១.០៥០.០០០ | ៥៣.៧៦០ | ៥៣២,៥៣% | ៣៤០,២៦% |

[២] ប្រភព៖ ធនាគារជាតិនៃកម្ពុជា
[៣] ប្រតិបត្តិការប័ណ្ណទូទាត់ រួមបញ្ចូលប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកជាមួយគ្នា

# ១ វឌ្ឍនភាពរបស់ប្រព័ន្ធទូទាត់សងប្រាក់

ស្របពេលការរីកចម្រើននៃបច្ចេកវិទ្យា ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់តាមរយៈកំណើននៃការដាក់ឱ្យប្រើនូវឧបករណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ។ កំណើននៃការដាក់ឱ្យប្រើនូវឧបករណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុនេះ បានធ្វើឱ្យប្រព័ន្ធទូទាត់សងប្រាក់ក្លាយជាធាតុសំខាន់មួយក្នុងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។ បច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ព្រមទាំងឧបករណ៍ទូទាត់ប្រកបដោយនវានុវត្តន៍ត្រូវបានដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់នៅប្រទេសកម្ពុជា។ អាស្រ័យហេតុនេះ ការអភិវឌ្ឍ និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ត្រូវបានធនាគារជាតិនៃកម្ពុជាចាត់ទុកជាការងារអាទិភាព។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់មួយចំនួនរួមមាន ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធធនាគារអនឡាញ (OBS) ប្រព័ន្ធបាគង (BAKONG) ប្រព័ន្ធរីថែលផេ (RETAIL PAY) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS)។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំ និងប្រព័ន្ធទូទាត់សងប្រាក់រួមដែលតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលបានដាក់ឱ្យដំណើរការកន្លងមកជាប្រព័ន្ធរង។

## ១.១. ការអភិវឌ្ឍថ្មីៗ

ប្រព័ន្ធផាត់ទាត់ជាតិត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជំនាន់ថ្មី ២.០ ក្នុងគោលបំណងពង្រឹងសុវត្ថិភាពប្រព័ន្ធ និងសមត្ថភាពផាត់ទាត់ឱ្យស្របទៅនឹងការអភិវឌ្ឍនៃវិស័យធនាគារនិងសេដ្ឋកិច្ច ក៏ដូចជាផ្តល់ភាពងាយស្រួលជាងមុនដល់សមាជិករបស់ប្រព័ន្ធ។ នៅក្នុងឆ្នាំ២០២៣ នេះ ប្រតិបត្តិការទូទាត់និងផាត់ទាត់មូលប្បទានបត្រ និងបញ្ជាអេឡិចត្រូនិកជាប្រាក់រៀលតាមប្រព័ន្ធផាត់ទាត់ជាតិមាននិន្នាការកើនឡើងទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ ខណៈការទូទាត់មូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកមានការថយចុះបន្តិច បើធៀបនឹងឆ្នាំ២០២២។ រីឯ ទំហំប្រាក់ទូទាត់តាមប្រព័ន្ធសេវាទូទាត់រហ័សមានការកើនឡើងវិញបន្ទាប់ពីការធ្វើទំនើបកម្មប្រព័ន្ធបានបញ្ចប់កាលពីឆ្នាំមុន។ ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់ប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេនអភិវឌ្ឍឡើងដើម្បីសម្រួលដល់ប្រតិបត្តិការឆ្លងគ្រឹះស្ថាន បង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់ សម្រួលប្រតិបត្តិការជាប្រាក់រៀល និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ប្រព័ន្ធបាគងបានបន្តពង្រីកសេវាកាន់តែទូលំទូលាយ និងមុខងារថ្មីៗដល់អ្នកប្រើប្រាស់ដូចជា ការប្តូរប្រាក់ក្នុងគណនីបាគងរវាងប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក និងការពិនិត្យមើលព័ត៌មានការចាក់វ៉ាក់សាំងកូវីដ-១៩។ ចំពោះប្រតិបត្តិការតាមរយៈប្រព័ន្ធបាគងបានបន្តកើនឡើងពីឆ្នាំទៅមួយឆ្នាំ ទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ ជាពិសេសប្រតិបត្តិការធ្វើឡើង

ជាប្រាក់រៀល។ ដោយឡែក ប្រព័ន្ធខេមបូខានស៊ែស្វីចដែលជាហេដ្ឋារចនាសម្ព័ន្ធប័ណ្ណទូទាត់ថ្នាក់ជាតិ សម្រាប់ធ្វើអន្តរប្រតិបត្តិការប័ណ្ណទូទាត់រវាងគ្រឹះស្ថានជាសមាជិក ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ក្នុងគោលបំណងសម្រួលដល់ការប្រើប្រាស់ប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក។

ស្របពេលជាមួយនឹងការដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធទូទាត់ថ្មីៗ ការទូទាត់តាមប្រព័ន្ធឌីជីថលនៅប្រទេសកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដែលបានកំពុងផ្លាស់ប្តូរបន្តិចម្តងៗក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសចាប់តាំងពីអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ដែលបានជួយសម្រួលដល់ប្រជាជនលើការទូទាត់ទំនិញ និងសេវានានា។ ការកើនឡើងនូវចំនួនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ បានជំរុញឱ្យមានការប្រកួតប្រជែងក្នុងការដាក់ឱ្យប្រើប្រាស់សេវាទូទាត់ឌីជីថលប្រកបដោយនវានុវត្តន៍ និងពង្រីកសេវាហិរញ្ញវត្ថុផ្លូវការកាន់តែទូលំទូលាយនៅក្នុងប្រទេស។ ភាពរីកចម្រើនទាំងនេះបានផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនកម្ពុជាឱ្យងាកមកប្រើប្រាស់ការទូទាត់ឌីជីថលជំនួសឱ្យក្រដាស់ប្រាក់ និងជាផ្នែកមួយដ៏សំខាន់ជួយគាំទ្រដល់សកម្មភាពធុរកិច្ច និងសេដ្ឋកិច្ចកម្ពុជាបានប្រសើរមួយកម្រិតទៀត។

**ក្រាហ្វ ១ - រូបិយវត្ថុក្នុងចរាចរ និងទំហំប្រាក់ទូទាត់តាមប្រព័ន្ធឌីជីថលជាប្រាក់រៀល**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) បានផ្តល់ឱកាសឱ្យបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ប្រកួតប្រជែងទាក់ទាញអតិថិជន តាមរយៈការដាក់ឱ្យប្រើប្រាស់សេវានិងឧបករណ៍ទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍ ក្នុងនោះមានដូចជា សេវាធនាគារតាមអ៊ីនធឺណិត សេវាធនាគារចល័ត សេវាទូទាត់ចល័ត ប័ណ្ណទូទាត់ និងការទូទាត់តាមយូអរកូត (QR Code)។ ការទូទាត់តាមយូអរកូត ជាមធ្យោបាយទូទាត់ថ្មីមួយដែលអតិថិជនពេញនិយម

ប្រើប្រាស់សម្រាប់ទូទាត់ទំនិញ-សេវានៅលើទីផ្សារ ជាពិសេសក្នុងស្រទាប់យុវវ័យដែលអាចសម្របខ្លួនក្នុងការទទួលយកនូវបច្ចេកវិទ្យាថ្មីនេះ។ ដោយមើលឃើញពីសារៈសំខាន់នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការ ខេអេចឃ្យូអរកូត (KHQR Code) ដែលជាស្តង់ដារឃ្យូអរកូតសម្រាប់ប្រទេសកម្ពុជា ក្នុងគោលបំណងលើកកម្ពស់អន្តរប្រតិបត្តិការនៃការទូទាត់តាមឃ្យូអរកូត និងរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ស្របតាមយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ និងតម្រង់ទិសឆ្ពោះទៅកាន់គោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលរបស់រាជរដ្ឋាភិបាល ឆ្នាំ២០២១-២០៣៥។ ទន្ទឹមនេះ ការដាក់ឱ្យដំណើរការខេអេចឃ្យូអរកូតក៏បានផ្តល់លទ្ធភាពសម្រាប់ប្រទេសកម្ពុជាក្នុងការធ្វើសមាហរណកម្មការទូទាត់ក្នុងតំបន់អាស៊ាន ដែលការទូទាត់តាមឃ្យូអរកូតនេះបានក្លាយជាការងារអាទិភាពមួយសម្រាប់ប្រទេសជាសមាជិកអាស៊ានធ្វើការភ្ជាប់ប្រព័ន្ធទូទាត់រវាងគ្នា។ ជាលទ្ធផល ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការនៃការទូទាត់ឆ្លងដែនតាមឃ្យូអរកូតរវាងប្រទេសកម្ពុជា និងប្រទេស/ក្រុមហ៊ុន រួមមាន ប្រទេសថៃ ឡាវ វៀតណាម ក្រុមហ៊ុនអន្តរជាតិយូញៀនផេ និងកំពុងបន្តអភិវឌ្ឍការតភ្ជាប់ប្រព័ន្ធជាមួយប្រទេស/ក្រុមហ៊ុនផ្សេងៗទៀត។

**ក្រាហ្វ ២ - ប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណទូទាត់ និងការស្កេន QR Code**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ១.២. គោលនយោបាយគាំទ្រ

នាយុគសម័យសកលភាវូបនីយកម្មឌីជីថល ដែលមានបដិវត្តន៍ឧស្សាហកម្ម ៤.០ ជានិន្នាការដឹកមុខ បច្ចេកវិទ្យាឌីជីថលបានបោះជំហានយ៉ាងលឿន ហើយបានក្លាយជាកត្តាគន្លឹះសម្រាប់ជំរុញការគ្រប់ដណ្តប់ និងការតភ្ជាប់សេដ្ឋកិច្ច និងសង្គមនៅទូទាំងពិភពលោកឱ្យកាន់តែស្អិតរមួត ខិតជិតគ្នា និងអាស្រ័យគ្នាទៅវិញទៅមក។ ម្យ៉ាងវិញទៀត ស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏មានភាពធូរស្រាល បានធ្វើឱ្យសេដ្ឋកិច្ចទូទាំងពិភពលោករួមទាំងប្រទេសកម្ពុជាចាប់ផ្តើមងើបឡើងវិញ។ ដើម្បីទ្រទ្រង់ដល់ការស្តារសេដ្ឋកិច្ចឡើងវិញ និងការរីកចម្រើនទៅមុខ ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ជាការងារអាទិភាពសំខាន់សម្រាប់ធនាគារជាតិនៃកម្ពុជា ក្នុងការផ្តល់មធ្យោបាយទូទាត់ប្រកបដោយនវានុវត្តន៍ មានភាពរឹងមាំ សុវត្ថិភាព និងប្រសិទ្ធភាព ដើម្បីសម្រួលការទូទាត់ពាណិជ្ជកម្មទាំងក្នុងប្រទេសនិងក្នុងតំបន់។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់សងប្រាក់មួយចំនួន ក្នុងគោលបំណងអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអ្នកប្រើប្រាស់មានលទ្ធភាពធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានទូលំទូលាយ។ ទោះជាយ៉ាងណា ការអនុវត្តគោលនយោបាយ និងលក្ខណៈបច្ចេកទេសរបស់ប្រព័ន្ធមួយចំនួន ជាកត្តារួមចំណែកបង្កការលំបាកសម្រាប់គ្រឹះស្ថាន និងអតិថិជនក្នុងការប្រើប្រាស់ផងដែរ។ ជាក់ស្តែង ប្រព័ន្ធផាត់ទាត់ជាតិត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជំនាន់ថ្មី ២.០ និងបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងគោលបំណងដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ការរីកចម្រើននៃបច្ចេកវិទ្យា បង្កើនសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធ និងធានាប្រសិទ្ធភាពក្នុងការធ្វើប្រតិបត្តិការបានប្រសើរជាងមុន។ សម្រាប់មុខងារដែលបានធ្វើបច្ចុប្បន្នកម្មនៅក្នុងប្រព័ន្ធផាត់ទាត់ជាតិជំនាន់ ២.០ នេះ រួមមាន ការរៀបចំជា Interface ថ្មី យន្តការ Failure Tolerance Mechanism ដែលបង្ហាញ Notification នៅពេលប្រព័ន្ធមានបញ្ហាផ្នែកណាមួយ ឬមានភាពមិនប្រក្រតីដែលទាមទារឱ្យធ្វើ Recovery និងមុខងារ Straight Through Processing (STP) ដែលសម្រួលដល់ការធ្វើប្រតិបត្តិការរបស់ប្រព័ន្ធលើការផ្តល់សេវាផាត់ទាត់មូលប្បទានបត្រ និងបញ្ជាទូទាត់អេឡិចត្រូនិកឱ្យកាន់តែមានភាពងាយស្រួល និងសុវត្ថិភាព។

ស្របពេលជាមួយគ្នានេះ ប្រព័ន្ធសេវាទូទាត់រហ័សក៏ត្រូវបានធ្វើទំនើបកម្មប្រព័ន្ធទៅជាប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មីផងដែរ និងបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ ដើម្បីអនុញ្ញាតឱ្យអតិថិជនមានលទ្ធភាពប្រើប្រាស់បានងាយស្រួល និងសុវត្ថិភាព។ ប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មីនេះបានបន្ថែមមុខងារថ្មីចំនួន ៣ រួមមាន៖ i/-ផ្តល់ជម្រើសដល់គ្រឹះស្ថានជាសមាជិកក្នុងការធ្វើប្រតិបត្តិការជាលក្ខណៈ Straight Through Processing (STP) ដែលអាចធ្វើប្រតិបត្តិការដោយផ្ទាល់និងភ្លាមៗទៅកាន់ប្រព័ន្ធធនាគារស្នូលរបស់គ្រឹះស្ថានសមាជិកដោយមិនប្រើ E-Token ii/-ផ្តល់នូវមុខងារពិនិត្យព័ត៌មានអតិថិជន (Customer Account Inquiries) ដែលជាយន្តការក្នុងការទប់ស្កាត់ការផ្ទេរប្រាក់ខុសគណនីដោយអតិថិជនអាចផ្ទៀងផ្ទាត់ជាថ្មីលើព័ត៌មានរបស់អ្នកទទួលផល

មុនពេលធ្វើប្រតិបត្តិការ និង iii/-អនុញ្ញាតឱ្យមានមុខងារធ្វើប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកសម្រាប់បំពេញតម្រូវការប្រើប្រាស់របស់អតិថិជន។ បន្ទាប់ពីការធ្វើបច្ចុប្បន្នកម្មរបស់ប្រព័ន្ធសេវាទូទាត់រហ័ស ឃើញថា គ្រឹះស្ថានសមាជិកទាំងអស់ប្រើប្រាស់ប្រព័ន្ធសេវាទូទាត់រហ័សកាន់តែមានភាពងាយស្រួលសម្រាប់អតិថិជន។

ដោយឡែក ពាក់ព័ន្ធនឹងប្រតិបត្តិការតាមប័ណ្ណទូទាត់នៅប្រទេសកម្ពុជា អតិថិជននៅតែពេញនិយមក្នុងការប្រើប្រាស់ប័ណ្ណទូទាត់ដើម្បីធ្វើការទូទាត់ទំនិញ និងប្រតិបត្តិការដាក់/ដកប្រាក់តាមម៉ាស៊ីនដាក់/ដកប្រាក់ស្វ័យប្រវត្តិ (ATM) ជាពិសេសការប្រើប្រាស់ប័ណ្ណឥណពន្ធ។ ក្នុងគោលបំណងសម្រួលដល់ការប្រើប្រាស់ប័ណ្ណឥណពន្ធក្នុងស្រុក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធខេមបូឌានស្វ៊ីចជាផ្លូវការ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ដែលអនុញ្ញាតឱ្យអ្នកកាន់ប័ណ្ណឥណពន្ធមានលទ្ធភាពប្រើប្រាស់ប័ណ្ណទូទាត់របស់ខ្លួនលើគ្រប់ម៉ាស៊ីន ATM និងម៉ាស៊ីនឆូតកាត (POS) របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកនៅក្នុងស្រុក។ ការដាក់ឱ្យដំណើរការប្រព័ន្ធនេះនឹងក្លាយជាកត្តាមួយជំរុញការទូទាត់វាយជាអេឡិចត្រូនិក កាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ បង្កើនប្រសិទ្ធភាពប្រព័ន្ធទូទាត់តាមរយៈការកាត់បន្ថយការវិនិយោគលើម៉ាស៊ីន ATM និង POS របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ លើកកម្ពស់អន្តរប្រតិបត្តិការ និងផ្តល់ភាពងាយស្រួលក្នុងការទូទាត់ទំនិញនិងសេវា។ ទោះបីជាយ៉ាងណា ការប្រើប្រាស់ប័ណ្ណឥណពន្ធក្នុងស្រុក ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយផងដែរ។ ជាក់ស្តែង ប័ណ្ណឥណពន្ធដែលប្រើប្រាស់បច្ចេកវិទ្យា Magnetic stripe ចេញផ្សាយដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងស្រុក នៅមិនទាន់ឆ្លើយតបទៅនឹងស្តង់ដារសុវត្ថិភាពទាំងស្រុងនៅឡើយ ដោយសារប្រព័ន្ធសុវត្ថិភាពរបស់បច្ចេកវិទ្យានេះនៅមានកម្រិត ដែលអាចបង្កឱ្យមានការលួចបន្លំផ្សេងៗក្នុងការធ្វើប្រតិបត្តិការរបស់អតិថិជន។ ដើម្បីលើកកម្ពស់សុវត្ថិភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ប័ណ្ណទូទាត់ឥណពន្ធនៅប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជាបានដាក់ចេញសេចក្តីជូនដំណឹងស្តីពី ការអនុវត្តគោលនយោបាយប្រព័ន្ធខេមបូឌានស្វ៊ីច ដើម្បីជំរុញគ្រឹះស្ថានសមាជិកប្រើប្រាស់ស្តង់ដារលេខ CSS-BIN និងប្រើប្រាស់ស្តង់ដារ EMV Chip សម្រាប់ចេញផ្សាយប័ណ្ណទូទាត់ក្នុងស្រុកជំនួសបច្ចេកវិទ្យា Magnetic stripe វិញ ការពង្រឹងសុវត្ថិភាពលើម៉ាស៊ីន ATM និង POS និងការផ្តល់ជម្រើសសម្រាប់ការទទួលយកនិងចេញផ្សាយប័ណ្ណទូទាត់រួមស្លាកសញ្ញារវាងប្រព័ន្ធខេមបូឌានស្វ៊ីច និងក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ។ ដោយពិនិត្យឃើញថាគ្រឹះស្ថានមួយចំនួននៅបន្តប្រើប្រាស់ប័ណ្ណឥណពន្ធដែលមានលេខអត្តសញ្ញាណធនាគារ (BIN) មិនមែនស្តង់ដារស្របតាមវិធាននិងនីតិវិធីប្រព័ន្ធខេមបូឌានស្វ៊ីច ដែលធនាគារជាតិនៃកម្ពុជាបានកំណត់ស្តង់ដារលេខអត្តសញ្ញាណធនាគារលើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក (៩១១៦) ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងស្តីពី ការផ្អាកដំណើរការលេខអត្តសញ្ញាណធនាគារ មិនមែនស្តង់ដារសម្រាប់ប័ណ្ណឥណពន្ធក្នុងស្រុករបស់ប្រព័ន្ធខេមបូឌានស្វ៊ីច កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់លេខអត្តសញ្ញាណធនាគារ ការ

អនុវត្តស្តង់ដារ និងឧត្តមានុវត្តអន្តរជាតិនៃការប្រើប្រាស់ប័ណ្ណឥណពន្ធរបស់ប្រព័ន្ធខេមបូខានស៊ែស្វីច នៅប្រទេសកម្ពុជា។ ជាមួយគ្នានេះ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍នៃបច្ចេកវិទ្យា ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអភិវឌ្ឍមុខងារ Contactless សម្រាប់ប្រព័ន្ធខេមបូខានស៊ែស្វីចដែលមានស្រាប់ និងបាន ដាក់ចេញសេចក្តីជូនដំណឹងស្តីពី ការអភិវឌ្ឍបន្ថែមមុខងារ Contactless លើប្រព័ន្ធខេមបូខានស៊ែស្វីច កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណងកំណត់ទំហំប្រាក់អតិបរមា និងកម្រៃសម្រាប់ ប្រតិបត្តិការ Contactless តាមប្រព័ន្ធខេមបូខានស៊ែស្វីច និងលើកទឹកចិត្តឱ្យគ្រឹះស្ថានសមាជិកចូលរួម អភិវឌ្ឍមុខងារនេះ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងសមត្ថភាពក្នុងការអនុវត្តមុខងារ គ្រប់គ្រងនិងត្រួតពិនិត្យបន្ថែមទៀតដើម្បីធានាថា ប្រព័ន្ធទូទាត់សងប្រាក់ដំណើរការប្រកបដោយ សុវត្ថិភាព ប្រសិទ្ធភាព និងទទួលបានការជឿទុកចិត្តពីសាធារណជន។

សម្រាប់ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់ពេញនិយមសម្រាប់ស្រទាប់យុវជននាពេលបច្ចុប្បន្ន ត្រូវបានបន្តធ្វើទំនើបកម្មប្រព័ន្ធជាបន្តបន្ទាប់ ដោយបានពង្រីកសេវាកាន់តែទូលំទូលាយ និងបន្ថែម មុខងារថ្មីៗដល់អ្នកប្រើប្រាស់ ដូចជា ការប្តូរប្រាក់ក្នុងគណនីបាគងរវាងប្រាក់រៀល និងប្រាក់ដុល្លារ អាមេរិក និងការពិនិត្យមើលព័ត៌មានការចាក់វ៉ាក់សាំងកូវីដ-១៩។ ស្របពេលជាមួយនឹងវឌ្ឍនភាព ទាំងនេះ ធនាគារជាតិនៃកម្ពុជាក៏បានបន្តអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ការទូទាត់ឆ្លងដែន និងបាន ដាក់ដំណើរការជាផ្លូវការជាមួយប្រទេសក្នុងតំបន់ និងដៃគូសហការ រួមមាន ប្រទេសថៃ ម៉ាឡេស៊ី ឡាវ វៀតណាម ក្រុមហ៊ុនអន្តរជាតិយូញៀនផេ និងកំពុងបន្តអភិវឌ្ឍគម្រោងទូទាត់ឆ្លងដែនជាមួយ បណ្តាប្រទេស/ក្រុមហ៊ុនផ្សេងទៀតដូចជា ប្រទេសចិន ជប៉ុន ឥណ្ឌា សិង្ហបុរី និងក្រុមហ៊ុនអាលីផេ។ ការអភិវឌ្ឍគម្រោងនេះនឹងផ្តល់ជាមធ្យោបាយសម្រួលការទូទាត់ឆ្លងដែនដល់អ្នកប្រើប្រាស់ដូចជា ភ្ញៀវទេសចរ ពលករ និងអ្នកធុរកិច្ច។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានកំពុងអភិវឌ្ឍប្រព័ន្ធបាគង តម្លៃធំ ក្នុងគោលបំណងជំរុញការប្រើប្រាស់សេវាទូទាត់សងប្រាក់ និងជំរុញឱ្យបុគ្គល និងធុរកិច្ច អាច ធ្វើប្រតិបត្តិការហិរញ្ញវត្ថុឌីជីថលបានកាន់តែប្រសើរជាងមុន ជាពិសេសប្រតិបត្តិការទូទាត់និងផ្ទេរ ប្រាក់ដែលមានទំហំប្រាក់ធំ។ ក្រៅពីភាពជោគជ័យនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សង ប្រាក់ខាងលើ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម ដើម្បីតភ្ជាប់ ហេដ្ឋារចនាសម្ព័ន្ធដែលបានដាក់ឱ្យដំណើរការកន្លងមកជាច្រកទូទាត់តែមួយដើម្បីសម្រួលដល់ ប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ឆ្លងគ្រឹះស្ថាន។ អតិថិជនអាចធ្វើប្រតិបត្តិការទូទាត់ និងផ្ទេរប្រាក់ ទាំងតម្លៃរាយ និងតម្លៃធំតាមបញ្ជរក៏ដូចជាតាមកម្មវិធីធនាគារចល័ត ឬទូរស័ព្ទចល័តរបស់គ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ ដោយប្រព័ន្ធទូទាត់សងប្រាក់រួមនឹងបែងចែកប្រតិបត្តិការទៅកាន់ប្រព័ន្ធរង ដោយស្វ័យប្រវត្តិ។ ជាមួយគ្នានេះ ដើម្បីគាំទ្រដល់កិច្ចដំណើរការនិងការគ្រប់គ្រងប្រព័ន្ធប្រកបដោយ ប្រសិទ្ធភាព និងជាចំណងផ្លូវច្បាប់ចំពោះគ្រប់សមាជិកទាំងអស់របស់ប្រព័ន្ធនេះ ធនាគារជាតិនៃកម្ពុជា បានកំពុងរៀបចំវិធាននិងនីតិវិធីរបស់ប្រព័ន្ធទូទាត់សងប្រាក់រួមសម្រាប់ដាក់ឱ្យអនុវត្តគ្រប់គ្រឹះស្ថាន សមាជិក។

ស្របពេលនៃការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ សេវាទូទាត់សងប្រាក់នៅកម្ពុជាមានសន្ទុះគួរឱ្យកត់សម្គាល់ ដែលការណ៍នេះអាចឃើញច្បាស់តាមរយៈការកើនឡើងនៃការដាក់ឱ្យប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗដូចជា សេវាធនាគារចល័ត និងសេវាទូទាត់ចល័ត សម្រាប់ការទូទាត់សងប្រាក់ឌីជីថលជាដើម។ កំណើននៃការដាក់ឱ្យប្រើនូវឧបករណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុនេះបានធ្វើឱ្យប្រព័ន្ធទូទាត់សងប្រាក់ក្លាយជាធាតុសំខាន់មួយក្នុងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។ បច្ចុប្បន្ន ឧបករណ៍ទូទាត់ប្រកបដោយនវានុវត្តន៍ដូចជា ប័ណ្ណទូទាត់ និងការទូទាត់តាមយូអរកូត ត្រូវបានដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់នៅប្រទេសកម្ពុជា។ ការទូទាត់តាមយូអរកូត ជាមធ្យោបាយទូទាត់ថ្មី ដែលកំពុងពេញនិយមសម្រាប់ប្រជាជនកម្ពុជា ជាពិសេសក្នុងស្រទាប់យុវវ័យប្រើប្រាស់សម្រាប់ទូទាត់ទំនិញ-សេវា ជាពិសេសចាប់តាំងពីការរីករាលដាលនៃជំងឺកូវីដ-១៩ បានក្លាយជាកត្តាដ៏សំខាន់មួយក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនកម្ពុជាឱ្យងាកមកប្រើប្រាស់ការទូទាត់ឌីជីថលជំនួសឱ្យសាច់ប្រាក់។ ទោះបីជាការទូទាត់តាមយូអរកូតផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនក៏ដោយ ក៏នៅមានបញ្ហាប្រឈមជាសារវន្តដែលទាមទារឱ្យមានការយកចិត្តទុកដាក់ ដោយសារបច្ចុប្បន្នគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ បានដាក់ឱ្យដំណើរការការទូទាត់តាមយូអរកូតនៅតាមហាងលក់ទំនិញរបស់ពាណិជ្ជករទូទាត់រាយ ប៉ុន្តែយូអរកូតទាំងនោះពុំទាន់មានលក្ខណៈស្តង់ដាររួមគ្នាអាចធ្វើប្រតិបត្តិការទូទាត់ឆ្លងប្រព័ន្ធគ្នាបាននៅឡើយ។ ដោយពិនិត្យឃើញនូវបញ្ហាប្រឈមនេះ និងភាពចាំបាច់ត្រូវដោះស្រាយដើម្បីបង្កើនសុវត្ថិភាព និងប្រសិទ្ធភាពនៃការទូទាត់តាមយូអរកូត ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការខេអេចយូអរកូត កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២ និងក្លាយជាចលករក្នុងការពន្លឿន និងលើកកម្ពស់ការទូទាត់តាមខេអេចយូអរកូត ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

ទន្ទឹមនឹងវឌ្ឍនភាពនៃប្រព័ន្ធទូទាត់សងប្រាក់ ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់ត្រូវបានអនុវត្តត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ដែលនេះជាតួនាទីចម្បងមួយផងដែររបស់ធនាគារជាតិនៃកម្ពុជា ក្នុងចំណោមតួនាទីផ្សេងៗទៀត។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ អនុវត្តឡើងក្នុងគោលបំណងរក្សាសុវត្ថិភាពនិងប្រសិទ្ធភាពរបស់ប្រព័ន្ធទាំងមូល និងដើម្បីធានាថាប្រព័ន្ធទាំងនោះគោរពតាមគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានរៀបចំសេចក្តី-ណែនាំ ព្រមទាំងវិធាននិងនីតិវិធីសម្រាប់ជាចំណងផ្លូវច្បាប់គ្រប់គ្រងលើការអនុវត្ត និងប្រតិបត្តិការរបស់ប្រព័ន្ធនីមួយៗ និងបានដាក់ចេញនូវក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលជាឯកសារមូលដ្ឋានបង្ហាញពីគោលដៅនៃគោលនយោបាយត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលអនុវត្តដោយធនាគារជាតិនៃកម្ពុជា ហើយក៏ជាគោលការណ៍ណែនាំសម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃពីកម្រិតហានិភ័យចម្បងៗក្នុងប្រព័ន្ធទូទាត់សងប្រាក់ ដោយអនុលោមទៅតាមគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការ

ប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។ ជាមួយនឹងការវិវត្តន៍យ៉ាងឆាប់រហ័សនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ បានធ្វើឱ្យមានការផ្លាស់ប្តូរបរិបទនៃការផ្តល់សេវាហិរញ្ញវត្ថុ ការដាក់ឱ្យដំណើរការសេវាទូទាត់ និងឧបករណ៍ទូទាត់ដែលប្រកបដោយនវានុវត្តន៍។ ការណ៍នេះ បានបង្កជាហានិភ័យថ្មីៗបន្ថែមទៀតដែលទាមទារឱ្យមានការប្រុងប្រយ័ត្នក្នុងការឆ្លើយតប ព្រោះភាពរអាក់រអួលនៃប្រព័ន្ធទូទាត់សងប្រាក់អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថិរភាពហិរញ្ញវត្ថុ ដែលនាំទៅដល់វិបត្តិហិរញ្ញវត្ថុជាយថាហេតុ។ ដូចនេះ ធនាគារជាតិនៃកម្ពុជាបានកំពុងរៀបចំសេចក្តីព្រាងការគ្រប់គ្រងផែនការនិរន្តរភាពសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា (BCM) ក្នុងគោលបំណងអាចបន្តដំណើរការរបស់ប្រព័ន្ធទូទាត់នៅពេលមានឧបទ្ទវហេតុណាមួយកើតឡើង ហើយដោះស្រាយបញ្ហាបានទាន់ពេលវេលា។

កំណើននៃការប្រើប្រាស់ឧបករណ៍ទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជានិងសេវាទូទាត់មានការកើនឡើងជាលំដាប់នាពេលបច្ចុប្បន្ននេះ ដោយសារតែការវិវត្តន៍នៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ដើម្បីគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់ ព្រមទាំងការផ្តល់សេវានិងឧបករណ៍ទូទាត់សងប្រាក់ និងដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាទាំងនោះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញបទប្បញ្ញត្តិលើវិស័យធនាគារនិងហិរញ្ញវត្ថុ តាមរយៈការរៀបចំ និងដាក់ចេញក្របខណ្ឌបទប្បញ្ញត្តិរឹងមាំ និងប្រកបដោយប្រសិទ្ធភាព។ នៅក្នុងឆ្នាំ២០២៣ សេចក្តីណែនាំស្តីពី "ការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់កិច្ចសហការផ្ទេរប្រាក់អន្តរជាតិ ក្នុងដំណាក់កាលសាកល្បង" ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីឱ្យការអនុវត្តមានលក្ខណៈស្តង់ដារ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំប្រកាសបន្ថែមទៀត ដែលក្នុងនោះរួមមាន ការកំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការគ្រប់គ្រងគណនីអាណត្តិព្យាបាល ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិការទីផ្សារឥណទានតាមប្រព័ន្ធអេឡិចត្រូនិក។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ចេញគោលការណ៍គ្រប់គ្រងហានិភ័យព័ត៌មានវិទ្យាសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីអនុវត្តក្នុងគោលបំណងពង្រឹងប្រព័ន្ធសុវត្ថិភាពផ្ទៃក្នុង ក្នុងការផ្តល់សេវាទូទាត់ឌីជីថលប្រកបដោយសុវត្ថិភាព។

បន្ទាប់ពីបានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ និងក្របខណ្ឌបទប្បញ្ញត្តិរួចមក ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថលជាកត្តាសំខាន់សម្រាប់ការអប់រំនៅក្នុងយុគសម័យឌីជីថល។ ការលើកកម្ពស់លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុដែលមានភាពល្អប្រសើរតាមរយៈបច្ចេកវិទ្យាហិរញ្ញវត្ថុ ទាមទារនូវការយល់ដឹងផ្នែកហិរញ្ញវត្ថុឌីជីថល ដើម្បីឱ្យសាធារណជនប្រើប្រាស់សេវាទាំងនោះឱ្យមានប្រសិទ្ធភាព និងជៀសវាងការឆបោក ការក្លែងបន្លំ ការប្រើប្រាស់ទិន្នន័យដោយគ្មានការអនុញ្ញាត និងការទទួលបានសេវាដោយមិនស្មើភាពគ្នាជាដើម។ ដូចនេះ ធនាគារជាតិនៃកម្ពុជាបានចុះផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ប្រព័ន្ធបាគងដល់សាធារណជនទូទៅនៅតាមខេត្ត-ក្រុងជារៀងរាល់ឆ្នាំ ដើម្បីបញ្ជ្រាបចំណេះដឹងហិរញ្ញវត្ថុឌីជីថលដល់អ្នកប្រើប្រាស់។

## ១.៣. ជំហានបន្ទាប់

ក្នុងគោលដៅសម្រេចបាននូវការអនុវត្តគោលនយោបាយដូចបានរៀបរាប់ខាងលើ ការផ្តល់ការគាំទ្រ មតិណែនាំ និងកិច្ចសហការយ៉ាងជិតស្និតជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកប្រព័ន្ធ និងភាគីពាក់ព័ន្ធទាំងអស់ ជាកត្តាសំខាន់ដែលធ្វើឱ្យគ្រឹះស្ថានសមាជិកមានលទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ស្របតាមវឌ្ឍនភាពប្រព័ន្ធទូទាត់សងប្រាក់ជំនាន់ថ្មីរបស់ធនាគារជាតិនៃកម្ពុជាតាមដំណាក់កាលនីមួយៗបានដោយជោគជ័យ។

ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុលោមតាមគោលនយោបាយរបស់ប្រព័ន្ធខេមបូឌានស៊ែស្វីចធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានវឌ្ឍនភាព និងសហការជាមួយគ្រឹះស្ថានសមាជិក និងភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហានានាដែលកើតមានឡើង ដើម្បីអាចឱ្យការអនុវត្តគោលនយោបាយដែលមានចែងក្នុងសេចក្តីជូនដំណឹងសម្រេចបានតាមគោលដៅ។

ធនាគារជាតិនៃកម្ពុជានឹងបន្តជំរុញ និងលើកកម្ពស់ការទូទាត់តាមប្រព័ន្ធបាគង និងការអនុវត្តស្តង់ដារខេអេចឃ្យូអរកូតដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីសម្រេចបានក្នុងការត្រៀមខ្លួនសម្រាប់ការធ្វើអន្តរប្រតិបត្តិការទូទាត់តាមរយៈឃ្យូអរកូតទាំងក្នុងប្រទេស និងក្នុងតំបន់។ ជាមួយគ្នានេះ ការអភិវឌ្ឍប្រព័ន្ធបាគងតម្លៃធំនៅតែជាការងារអាទិភាពរបស់ធនាគារជាតិនៃកម្ពុជាដើម្បីជំរុញអន្តរប្រតិបត្តិការដែលមានតម្លៃធំ និងត្រៀមខ្លួនក្នុងការតភ្ជាប់ប្រព័ន្ធជាមួយប្រទេសក្នុងតំបន់។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម ដើម្បីតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដែលបានដាក់ឱ្យដំណើរការកន្លងមកជាច្រកទូទាត់តែមួយ ដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់ទាំងតម្លៃរាយ និងតម្លៃធំ។ ឯកសារវិធាននិងនីតិវិធីសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់រួម កំពុងត្រូវបានរៀបចំ និងត្រៀមពិភាក្សាជាមួយបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មុននឹងដាក់ឱ្យដំណើរការប្រព័ន្ធ។

បន្ថែមលើការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ការថែរក្សាប្រព័ន្ធទូទាត់សងប្រាក់ឱ្យដំណើរការប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងនិរន្តរភាព ជាកត្តាចាំបាច់ដែលទាមទារឱ្យមានការប្រុងប្រយ័ត្នក្នុងការឆ្លើយតប ព្រោះភាពរអាក់រអួលនៃប្រព័ន្ធទូទាត់សងប្រាក់អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថិរភាពហិរញ្ញវត្ថុ ដែលនាំទៅដល់វិបត្តិហិរញ្ញវត្ថុជាយថាហេតុ។ ធនាគារជាតិនៃកម្ពុជាបានកំពុងរៀបចំសេចក្តីព្រាងការគ្រប់គ្រងផែនការនិរន្តភាពសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ក្នុងគោលបំណងអាចបន្តដំណើរការរបស់ប្រព័ន្ធទូទាត់នៅពេលមានឧបទ្ទវហេតុណាមួយកើតឡើង ហើយដោះស្រាយបញ្ហាបានទាន់ពេលវេលា។

ជាមួយនឹងការវិវត្តន៍ និងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ជាពិសេសលើសេវាទូទាត់សងប្រាក់ និងសេវាផ្ទេរប្រាក់ បានអភិវឌ្ឍយ៉ាងឆាប់រហ័ស ដែលការណ៍នេះបានផ្តល់

ឱកាសសម្រាប់ធនាគារជាតិនៃកម្ពុជាដែលជានិយ័តករ បន្តសិក្សា និងរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសមស្របថ្មីៗ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាទាំងនោះ។

បន្ថែមលើនេះ ដើម្បីជំរុញការប្រើប្រាស់សេវាទូទាត់ឌីជីថលប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ការបង្កើនការយល់ដឹងដល់សាធារណជនអំពីរបៀបប្រើប្រាស់ឱ្យបានទូលំទូលាយ ជាកត្តាចាំបាច់ និងទាមទារឱ្យមានការរៀបចំជាក្របខណ្ឌ និងផែនការសកម្មភាពផ្សេងៗក្រោមកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តផែនការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថលទទួលបានប្រសិទ្ធភាពខ្ពស់។

### ប្រអប់ ១ - ការអភិវឌ្ឍគម្រោង Financial Transparency Corridor

កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរី ដើម្បីអភិវឌ្ឍគម្រោង Financial Transparency Corridor (FTC)។ គម្រោងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្កើតហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីសម្រួលដល់ពាណិជ្ជកម្ម និងសេវាហិរញ្ញវត្ថុឆ្លងដែនសម្រាប់សហគ្រាសធុនតូចនិងមធ្យម (SME) រវាងប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា។ ក្រោមការអភិវឌ្ឍគម្រោង FTC គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅសិង្ហបុរីអាចធ្វើការវាយតម្លៃហិរញ្ញប្បទានលើអាជីវកម្មឆ្លងដែនរបស់ SME នៃប្រទេសសិង្ហបុរីជាមួយ SME នៃប្រទេសកម្ពុជា ដោយប្រើប្រាស់ព័ត៌មានទទួលបានពីគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈផ្លេតហ្វម FTC។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលផ្តល់សេវាដល់ SME នៅកម្ពុជាក៏អាចធ្វើការវាយតម្លៃហិរញ្ញប្បទាន ដោយប្រើប្រាស់ព័ត៌មានទទួលបានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅសិង្ហបុរីតាមរយៈផ្លេតហ្វម FTC ផងដែរ។ ការប្រើប្រាស់ផ្លេតហ្វម FTC នេះនឹងជួយសម្រួលដល់ SME នៅប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា ពង្រីកបណ្តាញពាណិជ្ជកម្មឌីជីថលកាន់តែទូលំទូលាយតាមរយៈបណ្តាញ Business Sans Border Proxtera និងផ្តល់ឱកាសដល់ការភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មកាន់តែប្រសើរក្នុងតំបន់អាស៊ាន និងតំបន់ផ្សេងៗទៀត។ ការអភិវឌ្ឍផ្លេតហ្វម FTC មានគោលបំណង (១)-បង្កើតហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់ផ្តល់ការព្រមព្រៀងជាមុន (Consent-based) ដើម្បីសម្រួលដល់ការដោះដូរព័ត៌មានរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលចូលរួមក្នុងផ្លេតហ្វមនៅក្នុងប្រទេសសិង្ហបុរី និងប្រទេសកម្ពុជាលើការផ្តល់សេវាហិរញ្ញវត្ថុឆ្លងដែនដល់ SME និង (២)-គាំទ្រការវាយតម្លៃឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុលើការផ្តល់ហិរញ្ញប្បទានពាណិជ្ជកម្ម និងការអនុលោមតាមបទប្បញ្ញត្តិស្តីពី ការប្រឆាំងការសម្អាតប្រាក់ ដើម្បីកាត់បន្ថយវិវាទពាណិជ្ជកម្ម និងហានិភ័យ។

ដើម្បីបន្តកិច្ចសហប្រតិបត្តិការនេះ ធនាគារជាតិនៃកម្ពុជាសហការជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរីបានរៀបចំសិក្ខាសាលាស្តីពី គម្រោង FTC ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួនពីរលើក ដោយលើកទីមួយធ្វើឡើងកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ នៅធនាគារជាតិនៃកម្ពុជា អាគារសែនសុខ និងលើកទីពីរ រៀបចំនៅអាគារ Expo ប្រទេសសិង្ហបុរី កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ដើម្បីស្វែងរកគ្រឹះស្ថានមានចំណាប់អារម្មណ៍ចូលរួមជាសមាជិកគម្រោង និងធ្វើតេស្តសាកល្បង។ សិក្ខាសាលាបានបង្ហាញពីហេដ្ឋារចនាសម្ព័ន្ធ ករណីសិក្សា ជាពិសេសសមាសធាតុសំខាន់ៗដើម្បីអនុវត្តគម្រោង FTC ដែលរួមមាន (១)-ការចែករំលែកទិន្នន័យ

តាមរយៈផ្លែតហ្វម FTC (២)-ការការពារទិន្នន័យ (៣)-សមាជិកភាពគម្រោង និង (៤)-ការងារអភិបាលកិច្ច។ លើសពីនេះ សិក្ខាសាលាបានបង្ហាញពី Proxtera ដែលជាផ្លែតហ្វមមានសមត្ថភាពផ្គូរផ្គងតម្រូវការ និងការផ្គត់ផ្គង់របស់ SME ពង្រីកវិសាលភាពទីផ្សារ និងសម្រួលការផ្តល់សេវាហិរញ្ញវត្ថុជាលក្ខណៈឌីជីថលជាមួយប្រទេសជាដៃគូទូទាំងពិភពលោក ដោយគ្រឹះស្ថានមានចំណាប់អារម្មណ៍អាចភ្ជាប់ជាលក្ខណៈទ្វេភាគីជាមួយផ្លេតហ្វម Proxtera ដោយមិនចាំបាច់មានការគាំទ្រ ឬសម្របសម្រួលពីធនាគារជាតិនៃកម្ពុជាឡើយ។ ផ្លែតហ្វម Proxtera ក៏រួមមានបញ្ចូលនូវ SME Financial Empowerment (SFE) Program ដែលជាកម្មវិធីផ្តល់ចំណេះដឹងសម្រាប់ MSME និង SME សម្រាប់លើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល និងសេវាហិរញ្ញវត្ថុ ដើម្បីគាំទ្រការអនុវត្តសេដ្ឋកិច្ចឌីជីថល SME ដែលមានចំណាប់អារម្មណ៍ត្រូវមានការគាំទ្រពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាដើម្បីចូលរួមក្នុងផ្លែតហ្វមនេះបាន ដោយចំណាយថវិកាតិចតួចលើការចូលរួមសិក្សាក្នុងផ្លែតហ្វម SFE នេះ។



# ២ នវានុវត្តន៍ប្រព័ន្ធបាគង

ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់នៅប្រទេសកម្ពុជា និងជំរុញនវានុវត្តន៍នៅក្នុងប្រព័ន្ធទូទាត់សងប្រាក់ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោង ជួយសម្រួលដល់ប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថាន បង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ប្រព័ន្ធបាគងត្រូវបានទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិថាជាប្រព័ន្ធទូទាត់ក្នុងយុគសម័យថ្មី ដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន (Blockchain) និងបច្ចេកវិទ្យាឌីអិលធី (Distributed Ledger Technology) ប្រកបដោយនវានុវត្តន៍ ផ្តល់នូវអត្ថប្រយោជន៍ផ្នែកសេវាហិរញ្ញវត្ថុយ៉ាងទូលំទូលាយ លើកកម្ពស់ការធ្វើប្រតិបត្តិការទូទាត់ក្នុងស្រុក និងការទូទាត់ឆ្លងប្រទេសបានយ៉ាងងាយស្រួល និងសុវត្ថិភាព។ ដើម្បីរួមចំណែកជំរុញបរិយាបន្នហិរញ្ញវត្ថុ ប្រសិទ្ធភាពប្រព័ន្ធទូទាត់ និងសមាហរណកម្មប្រព័ន្ធធនាគារកម្ពុជានៅក្នុងតំបន់និងពិភពលោក ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តអភិវឌ្ឍប្រព័ន្ធបាគង ដែលអាចបំពេញមុខងារកាន់តែសម្បូរបែប។

## ២.១. វឌ្ឍនភាពប្រព័ន្ធបាគង

គិតត្រឹមដំណាច់ឆ្នាំ២០២៣ ប្រព័ន្ធបាគងមានសមាជិកសរុបចំនួន ៧៤ គ្រឹះស្ថាន ដោយក្នុងនោះមានគ្រឹះស្ថានចំនួន ៥៨ បានដាក់ឱ្យដំណើរការជាផ្លូវការ និងគ្រឹះស្ថានចំនួន ១៦ ផ្សេងទៀតបាននិងកំពុងបន្តធ្វើសន្ធានកម្មប្រព័ន្ធ។



ក្នុងឆ្នាំ២០២៣ នេះ អតិថិជនចុះឈ្មោះប្រើប្រាស់ប្រព័ន្ធបាគងតាមរយៈកម្មវិធីបាគងមានចំនួន ៦០០,៦៣ ពាន់គណនី កើនឡើង ១៤,៩% បើធៀបនឹងឆ្នាំ២០២២។ ទន្ទឹមនេះ ចំនួនអតិថិជនដែលមានគណនីធនាគារ/កាបូបអេឡិចត្រូនិកនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហើយអាចធ្វើប្រតិបត្តិការតាមប្រព័ន្ធបាគង (Customer Reached) មានចំនួនប្រមាណ ២៧ លានគណនី ដែលប៉ាន់ប្រមាណស្មើនឹង ១៦០% នៃចំនួនប្រជាជនសរុប។

**ក្រាហ្វ ៣ - ចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់ជាមួយកម្មវិធីបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

រីឯប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ដែលធ្វើឡើងតាមរយៈប្រព័ន្ធបាគងមានចំនួន ២០០,៩៣ លានប្រតិបត្តិការ ក្នុងនោះប្រតិបត្តិការជាប្រាក់រៀលមានចំនួន ៦៨,៧៩ លានប្រតិបត្តិការ និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ១៣២,១៤ លានប្រតិបត្តិការ និងមានទំហំប្រាក់ជាប្រាក់រៀលប្រមាណ ៨១,០៥ ទ្រីលានរៀល និងទំហំប្រាក់ជាប្រាក់ដុល្លារអាមេរិកប្រមាណ ៥៣,៧៦ ប៊ីលានដុល្លារអាមេរិក ដែលទំហំប្រាក់សរុបនៅក្នុងឆ្នាំ២០២៣ ស្មើនឹង ២៣១% នៃផ.ស.ស។ ការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រព័ន្ធបាគងមានការកើនឡើងជាលំដាប់ បន្ទាប់ពីប្រព័ន្ធបាគងត្រូវបានដាក់ឱ្យដំណើរការ ដូចបានបង្ហាញក្នុងក្រាហ្វខាងក្រោម៖

## ក្រាហ្វ ៤ - ប្រតិបត្តិការធ្វើឡើងតាមរយៈប្រព័ន្ធបាគង




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ក្រាហ្វ ៥ - ទំហំប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិក មុនដាក់ និងបន្ទាប់ពីបានដាក់ដំណើរការជាផ្លូវការប្រព័ន្ធបាគង




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.២. នវានុវត្តន៍ប្រព័ន្ធបាគង

### ក). ការអភិវឌ្ឍមុខងារចុះឈ្មោះអតិថិជនជាអេឡិចត្រូនិក (e-KYC) តាមប្រព័ន្ធបាគង

ប្រព័ន្ធទូទាត់សងប្រាក់នៅប្រទេសកម្ពុជា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ បច្ចុប្បន្នមានគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បាននិងកំពុងដាក់ឱ្យប្រើប្រាស់នូវសេវាផលិតផលឧបករណ៍ទូទាត់ប្រកបដោយនវានុវត្តន៍ ដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការធនាគារប្រកបដោយភាពងាយស្រួល ដូចជាអតិថិជនអាចចុះឈ្មោះប្រើប្រាស់កម្មវិធីធនាគារចល័តតាមអនឡាញ ពិនិត្យសមតុល្យគណនី ធ្វើប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់តាមឃ្យូអរកូដ ទូទាត់បង់វិក្កយបត្រនានាបានកាន់យ៉ាងងាយស្រួល។ ទន្ទឹមនឹងផលិតផល និងសេវាទូទាត់សំបូរបែបក៏ដោយ ប៉ុន្តែការចុះឈ្មោះអតិថិជនតាមអនឡាញនៅតែមានបញ្ហាប្រឈមនៅឡើយ ដោយសារការអភិវឌ្ឍន៍នៃក្របខ័ណ្ឌសម្គាល់អត្តសញ្ញាណអតិថិជនជាឌីជីថល (E-KYC) របស់គ្រឹះស្ថាននីមួយៗនៅពុំទាន់មានប្រព័ន្ធអាចផ្ទៀងផ្ទាត់បញ្ជាក់ពីភាពត្រឹមត្រូវអត្តសញ្ញាណអតិថិជនឡើយ។

ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈការចុះអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល និងពិនិត្យលទ្ធភាពប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) ដើម្បីសិក្សាពីការចែករំលែកទិន្នន័យអត្តសញ្ញាណសាធារណជនសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនឌីជីថល។ ដូច្នេះ នៅពេលអតិថិជនចុះឈ្មោះប្រើប្រាស់ប្រព័ន្ធបាគង ប្រព័ន្ធបាគងនឹងបញ្ជូនទិន្នន័យទៅថ្នាល CamDX ហើយបន្ទាប់មកថ្នាល CamDX នឹងធ្វើការផ្ទៀងផ្ទាត់ទិន្នន័យទាំងនោះជាមួយទិន្នន័យអត្តសញ្ញាណកម្មរបស់ក្រសួងមហាផ្ទៃ។ កិច្ចសហការនេះនឹងផ្តល់ជាកាលានុវត្តភាពដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាជំរុញនវានុវត្តន៍លើសេវាហិរញ្ញវត្ថុ ដើម្បីពង្រឹងការកំណត់អត្តសញ្ញាណអតិថិជនឌីជីថលសម្រាប់ផ្ទៀងផ្ទាត់នៅក្នុងវិស័យធនាគារ និងដើម្បីកាត់បន្ថយហានិភ័យក្នុងការក្លែងបន្លំ និងការប្រព្រឹត្តបទល្មើសបច្ចេកវិទ្យាផ្សេងៗ។



### ខ). ការអភិវឌ្ឍមុខងារបង្ហាញព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងប្រព័ន្ធបាគង

ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងសុខាភិបាល (គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស) ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល តាមរយៈការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ តំណភ្ជាប់សម្រាប់ស្វែងរកមើលព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ តាមប្រព័ន្ធបាគង ដែលផ្តល់លទ្ធភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលបានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធបាគង បានបំពេញព័ត៌មាន និងអត្តសញ្ញាណពេញលេញ (Full KYC) អាចស្វែងរកមើលព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ បានឆាប់រហ័ស ត្រឹមត្រូវ ច្បាស់លាស់ បើទោះបីជាពុំបានយកប័ណ្ណចាក់វ៉ាក់សាំងមកតាមខ្លួនក៏ដោយ។ បច្ចុប្បន្ន អតិថិជនចុះឈ្មោះប្រើប្រាស់បាគងបានពេញលេញ (Bakong Full KYC) មានចំនួន ៨៤,៧៩ ពាន់នាក់ អាចពិនិត្យមើលព័ត៌មានចាក់វ៉ាក់សាំងបានយ៉ាងងាយស្រួល។ សម្រាប់ជំហានបន្ទាប់ ធនាគារជាតិនៃកម្ពុជានឹងបន្តសហការអភិវឌ្ឍមុខងារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការចាក់វ៉ាក់សាំងកូវីដ-១៩ តាមកម្មវិធីបាគងបានផងដែរ។




### គ). ការអភិវឌ្ឍសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រមុខងារបាគង (Linking Account)

នៅក្នុងប្រទេសកម្ពុជា គ្រឹះស្ថានធនាគារភាគច្រើនកំពុងប្រើប្រាស់សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រនៅក្នុងប្រតិបត្តិការរបស់ខ្លួន ជាពិសេសប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់វិក្កយបត្រ និងការពិនិត្យសមតុល្យគណនី។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅពុំទាន់មានគោលការណ៍ណែនាំជាផ្លូវការណាមួយក្នុងការគ្រប់គ្រងសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រនៅឡើយ។ ជាទូទៅ គ្រឹះស្ថានធនាគារបានបង្កើតសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រសម្រាប់ប្រើប្រាស់ផ្ទៃក្នុង និងជាមួយដៃគូតែប៉ុណ្ណោះ។ ប្រព័ន្ធបាគង ជាគម្រោងផ្តួចផ្តើមក្នុងការលើកកម្ពស់ការកអភិវឌ្ឍសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រនៅក្នុងប្រព័ន្ធធនាគារនៅកម្ពុជាទាំងមូល។ តាមរយៈប្រព័ន្ធបាគងបានផ្តល់នូវសុវត្ថិភាព និងភាពងាយស្រួលសម្រាប់អតិថិជនក្នុងការពិនិត្យសមតុល្យ និងធ្វើប្រតិបត្តិការទូទាត់ពីគណនីមួយទៅគណនីមួយរបស់ធនាគារជាច្រើននៅក្នុងកម្មវិធីបាគងតែមួយដោយប្រើការភ្ជាប់សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (API Linking Account)។ ការអភិវឌ្ឍនេះអនុញ្ញាតឱ្យអតិថិជនងាយស្រួលក្នុងការគ្រប់គ្រងមូលនិធិ និងធ្វើប្រតិបត្តិការទូទាត់គ្រប់គណនីរបស់អតិថិជន។ បច្ចុប្បន្ននេះ កម្មវិធីបាគងត្រូវបានធ្វើបច្ចុប្បនភាពដល់ជំនាន់ ៣.៨ រួចរាល់ ដែលមានភ្ជាប់សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ ជាមួយប្រព័ន្ធធនាគារស្នូលរបស់សមាជិករួចរាល់ហើយ។

### ឃ). ប្រព័ន្ធបាគងជាច្រកទូទាត់ ក្នុងផ្សារពាណិជ្ជកម្មអេឡិចត្រូនិក (CambodiaTrade)




ដើម្បីគាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមក្នុងការលើកកម្ពស់ពង្រីកមុខងារការទូទាត់តាមប្រព័ន្ធបាគងជាមួយផ្សារពាណិជ្ជកម្មអេឡិចត្រូនិក (CambodiaTrade) តាមរយៈការតភ្ជាប់ប្រព័ន្ធបាគងជាច្រកទទួលការទូទាត់សម្រាប់ប្រតិបត្តិការទិញ-លក់ផលិតផលលើផ្លែតហ្វមផ្សារ CambodiaTrade និងបានផ្តល់ការបណ្តុះបណ្តាលដល់សហគ្រាសធុនតូចនិងមធ្យមអំពីការប្រើប្រាស់ប្រព័ន្ធបាគងជាច្រកទូទាត់សម្រាប់ទិញ-លក់ផលិតផលក្នុងផ្សារពាណិជ្ជកម្មអេឡិចត្រូនិក។ តាមរយៈកិច្ចសហការដ៏មានសារៈសំខាន់នេះ សហគ្រាសធនតូចនិងមធ្យមអាចមានលទ្ធភាពដាក់លក់ និងទិញផលិតផលក្នុងស្រុក ជាពិសេសផលិតផលកសិកម្ម និងទទួលបានការទូទាត់ភ្លាមៗតាមប្រព័ន្ធបាគងយ៉ាងមានប្រសិទ្ធភាពពីគ្រប់អតិថិជននៅទូទាំងប្រទេសកម្ពុជា។ ការណ៍នេះនឹងរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្ម ដែលជាវិស័យអាទិភាពមួយរបស់គោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាប្រកបដោយភាពធន់ចីរភាព និងបរិយាបន្ន។ ផ្សារពាណិជ្ជកម្មអេឡិចត្រូនិកត្រូវបានដាក់ឱ្យដំណើរការនៅក្នុងខែមីនា ឆ្នាំ២០២២ និងបានធ្វើសន្ទានកម្មយ៉ាងពេញលេញប្រកបដោយភាពជោគជ័យជាមួយប្រព័ន្ធបាគង។

### ង). ការពង្រីកមុខងារប្រព័ន្ធបាគងជាច្រកទូទាត់ជាមួយអគ្គនាយកដ្ឋានពន្ធដារ

ធនាគារជាតិនៃកម្ពុជាបានសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការសម្របសម្រួលរៀបចំមធ្យោបាយប្រមូលពន្ធតាមរយៈការទូទាត់តាមប្រព័ន្ធបាគង។ ប្រព័ន្ធបាគងត្រូវបានទទួលស្គាល់ថាជាប្រព័ន្ធទូទាត់កន្លែង ធ្វើប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថានបានយ៉ាងងាយស្រួល បច្ចុប្បន្នមានសមាជិកគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រមាណ ៧៩ គ្រឹះស្ថាន បានតភ្ជាប់គ្នាក្នុងប្រព័ន្ធតែមួយ ការណ៍នេះបានផ្តល់ភាពងាយស្រួលដល់ការបង់ពន្ធដាររបស់សាធារណជនតាមបែបឌីជីថលប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។

## ប្រអប់ ២ - ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ប្រព័ន្ធបាគង

ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់លទ្ធភាពដល់សាធារណជនទទួលបានសេវាហិរញ្ញវត្ថុដែលមានភាពល្អប្រសើរតាមរយៈបច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងបានរួមចំណែកដល់ការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ តម្លាភាព និងចំគោលដៅ ប្រកបដោយប្រសិទ្ធភាព ដែលនឹងចូលរួមកាត់បន្ថយភាពក្រីក្រ លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ និងជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេស ព្រមទាំងបញ្ចៀសពីការឆបោក ការក្លែងបន្លំ ការប្រើប្រាស់ទិន្នន័យដោយគ្មានការអនុញ្ញាតជាដើម។ សម្រាប់ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានបន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយតាមបណ្តាខេត្ត ស្តីពី ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ប្រព័ន្ធបាគង ចំនួនបីលើក រួមមាន ខេត្តកំពត ខេត្តកំពង់ធំ និងខេត្តកោះកុង តាមរយៈការរៀបចំជាបទបង្ហាញ កម្មវិធីសំនួរ-ចម្លើយ និងស្តង់ផ្សព្វផ្សាយជាសាធារណៈ ដោយមានការចូលរួមពីមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា តំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សិស្សានុសិស្ស និងសាធារណជនទូទៅប្រមាណជិត ៥០០ រូប។









# ៣ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់

ស្របតាមវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធនាគារ ប្រព័ន្ធទូទាត់សងប្រាក់ ដើរតួនាទីយ៉ាងសំខាន់ដើម្បីរក្សាប្រសិទ្ធភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចទាំងមូល។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាតួនាទីចម្បងមួយផងដែររបស់ធនាគារជាតិនៃកម្ពុជាក្នុងចំណោមតួនាទីផ្សេងៗទៀត និងអនុវត្តឡើងក្នុងគោលបំណងរក្សាសុវត្ថិភាព និងប្រសិទ្ធភាពរបស់ប្រព័ន្ធទាំងមូល។ ហេតុដូចនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដោយអនុលោមទៅតាមគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។

ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលជាឯកសារមូលដ្ឋានបង្ហាញពីគោលការណ៍ណែនាំសម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃពីកម្រិតហានិភ័យចម្បងៗក្នុងប្រព័ន្ធទូទាត់សងប្រាក់។ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់នៅប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជាបាននិងបន្តធ្វើការអភិវឌ្ឍនិងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ដែលបច្ចុប្បន្នត្រូវបានដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់ រួមមាន៖

## ៣.១. ការត្រួតពិនិត្យតាមដានប្រព័ន្ធទូទាត់សងប្រាក់

### ក). ប្រព័ន្ធផាត់ទាត់ជាតិ (NCS)

ប្រព័ន្ធផាត់ទាត់ជាតិ បានរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រួលដល់ការផាត់ទាត់ និងទូទាត់ជាលក្ខណៈមជ្ឈការលើប្រតិបត្តិការអន្តរធនាគារ តាមរយៈឧបករណ៍ទូទាត់សងប្រាក់ជាមូលប្បទានបត្រ និងបញ្ជាផ្ទេរឥណទានទាំងជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក រវាងគ្រឹះស្ថានជាសមាជិកនៃប្រព័ន្ធផាត់ទាត់ជាតិប្រកបដោយប្រសិទ្ធភាព និងភាពងាយស្រួល។ ប្រព័ន្ធផាត់ទាត់ជាតិមានគ្រឹះស្ថានជាសមាជិកចំនួន ៦១ ដែលក្នុងនោះ ៤៣ គ្រឹះស្ថានជាសមាជិកផ្ទាល់ និង ១៨ ជាសមាជិកមិនផ្ទាល់។

#### - មូលប្បទានបត្រ

ក្នុងឆ្នាំ២០២៣ ចំនួនមូលប្បទានបត្រជាប្រាក់រៀលដែលបានឆ្លងកាត់ការផាត់ទាត់ និងទូទាត់តាមរយៈប្រព័ន្ធផាត់ទាត់ជាតិមានចំនួន ៣៤.១០៩ សន្លឹក (កើនឡើង ១,៥%) និងទំហំប្រាក់ ២២.០០២,៧៤ ប៊ីលានរៀល (កើនឡើង ១០,៩%)។ ទន្ទឹមនោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់រៀលមាន ១៥៤ សន្លឹក (កើនឡើង ១២៦%) និងទំហំប្រាក់ ១៣៤,១៧ ប៊ីលានរៀល (កើនឡើង ៥០,៩%)។

ជាមួយគ្នានេះ ចំនួនមូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកមានចំនួន ១.០៩១.៧១០ សន្លឹក (ថយចុះ ៥,៨%) និងទំហំប្រាក់មានចំនួន ៩៩.៩៣៣,១៩ លានដុល្លារអាមេរិក (ថយចុះ ១៧,៥%)។ ទន្ទឹមនោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់ដុល្លារអាមេរិកមាន ១១.៥៩៧ សន្លឹក (កើនឡើង ៣២,៧%) និងទំហំប្រាក់មានចំនួន ៨៨០,៦១ លានដុល្លារអាមេរិក (ថយចុះ ៥០,១%)។ ទំហំប្រាក់សរុបរបស់មូលប្បទានបត្រដែលធ្វើប្រតិបត្តិការតាមប្រព័ន្ធផាត់ទាត់ជាតិនៅក្នុងឆ្នាំ២០២៣ មានទំហំ ១៥៥,៧% នៃផ.ស.ស។

**ក្រាហ្វ ៦ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

យោងតាមក្រាហ្វខាងលើបង្ហាញថា មូលប្បទានបត្រដែលធ្វើប្រតិបត្តិការផាត់ទាត់ និងទូទាត់នៅក្នុងប្រព័ន្ធផាត់ទាត់ជាតិជាប្រាក់រៀលមានការកើនឡើងទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ រីឯមូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកមាននិន្នាការថយចុះទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ បើធៀបនឹងឆ្នាំ២០២២។ ទោះបីមូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកមានការថយចុះបន្តិច ក៏ប៉ុន្តែមូលប្បទានបត្រជារួមនៅតែជាឧបករណ៍ទូទាត់សងប្រាក់ដែលពេញនិយមប្រើប្រាស់សម្រាប់ការទូទាត់ក្នុងសេដ្ឋកិច្ច។

ដោយសារមូលប្បទានបត្រនៅតែជាឧបករណ៍ទូទាត់សងប្រាក់ដែលមានហានិភ័យខ្ពស់ជាងឧបករណ៍ទូទាត់ដទៃ ដូច្នេះ ធនាគារជាតិនៃកម្ពុជានៅតែបន្តអនុវត្តវិធានការមួយចំនួនដើម្បីកាត់បន្ថយការប្រើប្រាស់មូលប្បទានបត្រ តាមរយៈការលើកទឹកចិត្តឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក និងបន្តជំរុញឱ្យគ្រឹះស្ថានជាសមាជិកពង្រឹងការអនុវត្តលក្ខខណ្ឌទាក់ទងនឹងការប្រើប្រាស់មូលប្បទានបត្រ តាមដានសមតុល្យគណនីជាប្រចាំ និងសិក្សាពីវិធានការនានាដើម្បីទប់ស្កាត់និងកាត់បន្ថយឱ្យបានជាអតិបរមានូវចំនួនមូលប្បទានបត្របង្វិលវិញ។

### - បញ្ជាផ្ទេរប្រាក់ជាអេឡិចត្រូនិក

ក្នុងឆ្នាំ២០២៣ ចំនួនប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់រៀលមាន ២៨.៣៣៩ ប្រតិបត្តិការ (កើនឡើង ២៥,៧%) និងទំហំប្រាក់មានចំនួន ៤.៨៧៦,៩៣ ប៊ីលានរៀល (កើនឡើង ៦,៩%)។ ជាមួយគ្នានេះ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិកមាន ៦៣២.០០៩ ប្រតិបត្តិការ (ថយចុះ ៦,៤%) និងទំហំប្រាក់មានចំនួន ១៣.១១៧,៩៨ លានដុល្លារអាមេរិក (កើនឡើង ៦,៥%)។ ទំហំប្រាក់សរុបរបស់បញ្ជាផ្ទេរឥណទានដែលធ្វើតាមប្រព័ន្ធផាត់ទាត់ជាតិនៅក្នុងឆ្នាំ២០២៣ មានទំហំ ៤៤,៧% នៃផ.ស.ស។

**ក្រាហ្វ ៧ - បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០២៣ នេះ ចំនួនបញ្ជាផ្ទេរ និងទំហំប្រាក់ជាប្រាក់រៀលមាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២២។ ដោយឡែក ចំពោះបញ្ជាផ្ទេរជាប្រាក់ដុល្លារអាមេរិក ចំនួនប្រតិបត្តិការមានការថយចុះ ប៉ុន្តែទំហំប្រាក់នៅតែបន្តកើនឡើងដដែល។ ដើម្បីបន្តជំរុញការប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិក ធនាគារជាតិនៃកម្ពុជាបាននិងកំពុងដាក់ចេញគោលការណ៍មួយចំនួនដូចជា ពង្រីកបណ្តាញផ្តល់សេវាបញ្ជាផ្ទេរប្រាក់តាមរយៈសេវាធនាគារអ៊ីនធឺណិត ឬសេវាធនាគារចល័ត ដើម្បីបង្កើនភាពងាយស្រួលសម្រាប់អតិថិជនប្រើប្រាស់ និងលើកទឹកចិត្តក្នុងការប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិក តាមរយៈការយកកម្រៃប្រតិបត្តិការតិចជាងប្រតិបត្តិការមូលប្បទានបត្រ។

### ខ). ប្រព័ន្ធសេវាទូទាត់រហ័ស (FAST)

គិតត្រឹមឆ្នាំ២០២៣ ប្រព័ន្ធសេវាទូទាត់រហ័សមានសមាជិកសរុបចំនួន ៥៧ គ្រឹះស្ថាន ដែលក្នុងនោះមានគ្រឹះស្ថានចំនួន ៣៥ បានដាក់ដំណើរការជាផ្លូវការ។ គួរបញ្ជាក់ផងដែរថា ប្រព័ន្ធសេវាទូទាត់រហ័សត្រូវបានដាក់ឱ្យប្រើប្រាស់ចាប់តាំងពីឆ្នាំ២០១៦ និងត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជាប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី (FAST 2.0) ដែលបានដាក់ឱ្យដំណើរការ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ កន្លងទៅ ក្នុងគោលបំណងដើម្បីសម្រួលដល់ការធ្វើប្រតិបត្តិការផ្ទេរមូលនិធិអន្តរធនាគារជាប្រាក់រៀល និងសម្រួលឱ្យអតិថិជនអាចទទួលបានមូលនិធិភ្លាមៗ។ សម្រាប់ប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មីនេះ មានបន្ថែមមុខងារ និងលក្ខណៈពិសេសមួយចំនួន ក្នុងការសម្រួលដល់ការធ្វើប្រតិបត្តិការប្រព័ន្ធសេវាទូទាត់រហ័សឱ្យកាន់តែប្រសើរជាងមុន។

ក្នុងឆ្នាំ២០២៣ បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធសេវាទូទាត់រហ័សមានប្រមាណ ២០.០៩១ ប្រតិបត្តិការ (ថយចុះ ១១,៦%) និងទំហំប្រាក់មានចំនួនប្រមាណ ៨៣,២៨ ប៊ីលានរៀល (កើនឡើង ១៦%) ស្មើនឹង ០,០៦% នៃផ.ស.ស។

**ក្រាហ្វ ៨ - បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធ FAST**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

យោងតាមទិន្នន័យក្នុងក្រាហ្វខាងលើបានបង្ហាញថា ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់រៀល ដែលធ្វើឡើងតាមរយៈប្រព័ន្ធសេវាទូទាត់រហ័សមានការថយចុះ ដោយសារប្រព័ន្ធនេះត្រូវបានធ្វើទំនើបកម្ម ហើយទើបនឹងដាក់ឱ្យដំណើរការជាបណ្តើរៗឡើងវិញ ប៉ុន្តែទំហំប្រាក់បញ្ជាផ្ទេរឥណទានជាប្រាក់រៀលនៅបន្តការកើនឡើង ដែលបង្ហាញឱ្យឃើញថាការប្រើប្រាស់តាមរយៈប្រព័ន្ធសេវាទូទាត់រហ័សនៅមានការពេញនិយមសម្រាប់អតិថិជនទូទៅ ក៏ដូចជាពាណិជ្ជករទូទាត់រាយសម្រាប់ធ្វើប្រតិបត្តិការទូទាត់ជាប្រាក់រៀល។

### គ). ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS)

ប្រព័ន្ធខេមបូឌានស៊ែស្វីចត្រូវបានដាក់ឱ្យដំណើរការបឋមកាលពីឆ្នាំ២០១៧ និងបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៅពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ដែលជាគំនិតផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជាក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ ឆ្លើយតបទៅនឹងការរីកចម្រើននៃសេដ្ឋកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ គិតត្រឹមឆ្នាំ២០២៣ ប្រព័ន្ធខេមបូឌានស៊ែស្វីចមានសមាជិកសរុបចំនួន ៦០ គ្រឹះស្ថាន ដែលក្នុងនោះមានគ្រឹះស្ថានចំនួន ៤១ (សមាជិកផ្ទាល់ ៣៩ គ្រឹះស្ថាន និងសមាជិកមិនផ្ទាល់ចំនួន ២) បានដាក់ឱ្យដំណើរការប្រព័ន្ធជាផ្លូវការ ខណៈគ្រឹះស្ថានសមាជិកដទៃទៀតកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍផ្សេងៗគ្នា។ ប្រព័ន្ធខេមបូឌានស៊ែស្វីច ជា Local Switch ត្រូវបានអភិវឌ្ឍឡើងដើម្បីផ្តល់ជាមធ្យោបាយងាយស្រួលសម្រាប់អតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ធ្វើប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថានតាមប័ណ្ណទូទាត់ឥណពន្ធខេមបូឌានស៊ែស្វីចលើគ្រប់ម៉ាស៊ីនដាក់/ដកប្រាក់ (ATM) និងម៉ាស៊ីនឆូតកាត (POS) របស់គ្រឹះស្ថានសមាជិក និងជា Switch ដើម្បីធ្វើសមាហរណកម្មជាមួយប្រទេសក្នុងតំបន់។

ក្នុងឆ្នាំ២០២៣ នេះ ប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់រៀលដែលបានចូលទូទាត់តាមប្រព័ន្ធខេមបូឌានស៊ែស្វីចមានចំនួន ២៨០.៨១៨ ប្រតិបត្តិការ (ថយចុះ ២៥,៥%) និងទំហំប្រាក់មានចំនួន ៦២,៧៨ ប៊ីលានរៀល (ថយចុះ ២៧,២%)។ ជាមួយគ្នានេះ ចំនួនប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥៥.២៧០ ប្រតិបត្តិការ (ថយចុះ ៣៤,៨%) និងទំហំប្រាក់មានចំនួន ៧,៥៥ លានដុល្លារអាមេរិក (ថយចុះ ៣៦,៣%)។ ទំហំប្រាក់សរុបធ្វើប្រតិបត្តិការតាមប្រព័ន្ធខេមបូឌានស៊ែស្វីចនៅក្នុងឆ្នាំ២០២៣ មានទំហំប្រមាណ ០,០៧% នៃផ.ស.ស។

**ក្រាហ្វ ៩ - ប្រតិបត្តិការប័ណ្ណឥណពន្ធ តាមប្រព័ន្ធខេមបូឌានស៊ែរស្វិច**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឃ). ប្រព័ន្ធធនាគារអនឡាញ (OBS)

គិតត្រឹមឆ្នាំ២០២៣ ប្រព័ន្ធធនាគារអនឡាញមានសមាជិកសរុបចំនួន ៨៣ គ្រឹះស្ថាន ដែលក្នុងនោះមានធនាគារពាណិជ្ជចំនួន ៥៦ ធនាគារឯកទេសចំនួន ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ១៧ និងស្ថាប័នរដ្ឋចំនួន ១ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។

ក្នុងឆ្នាំ២០២៣ ការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញមានចំនួន ៦៧.៩៩៩ ប្រតិបត្តិការ ដែលក្នុងនោះការផ្ទេរប្រាក់ក្នុងចំណោមគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមាន ៦៧.០៤៧ ប្រតិបត្តិការ និងការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្តមាន ៩៥២ ប្រតិបត្តិការ។ ការផ្ទេរប្រាក់ជាប្រាក់រៀលរវាងគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមានចំនួន ៤៣.៤៣៩ ប្រតិបត្តិការ (កើនឡើង ២៩,៣%) ស្មើនឹងទំហំប្រាក់ ១១៦,៨៩ ទ្រីលានរៀល (កើនឡើង ២៨,២%) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ២៣.៦០៨ ប្រតិបត្តិការ (កើនឡើង ១៨%) ស្មើទំហំប្រាក់ ៦២.៩១៦,៥៦ លានដុល្លារអាមេរិក (កើនឡើង ៥,៧%)។ ក្នុងរយៈពេលដូចគ្នានេះ ប្រតិបត្តិការផ្ទេរប្រាក់ជាប្រាក់រៀល ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត

មានចំនួន ៨៨៥ ប្រតិបត្តិការ (ថយចុះ ១២,៥%) ស្មើទំហំប្រាក់ ៤,៧៤ ទ្រីលានរៀល (កើនឡើង ៨៩,៦%) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥៦៧ ប្រតិបត្តិការ (ថយចុះ ១២,៤%) ស្មើទំហំប្រាក់ ២.១០៥,៧៥ លានដុល្លារអាមេរិក (កើនឡើង ១១៤,៦%)។ ទំហំប្រាក់សរុបធ្វើប្រតិបត្តិការតាមប្រព័ន្ធធនាគារអនឡាញ នៅក្នុងឆ្នាំ២០២៣ មានទំហំប្រមាណ ២៩៧,៦% នៃផ.ស.ស។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប្រព័ន្ធធនាគារអនឡាញនៅតែជាប្រព័ន្ធដែលមានប្រជាប្រិយភាព។ ទោះបីជាយ៉ាងណាក៏ដោយ ធនាគារជាតិនៃកម្ពុជានៅតែបន្តជំរុញឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់ប្រព័ន្ធនេះឱ្យបានកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព ដើម្បីជំរុញការទូទាត់សងប្រាក់ជាអេឡិចត្រូនិក និងសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ឱ្យកាន់តែងាយស្រួល និងសុវត្ថិភាព។

**ក្រាហ្វ ១០ - ប្រតិបត្តិការផ្ទេរប្រាក់ តាមប្រព័ន្ធធនាគារអនឡាញ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ង). ប្រព័ន្ធរីថែលផេ (Retail Pay)

ប្រព័ន្ធរីថែលផេត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ដែលប្រព័ន្ធនេះមានប្រព័ន្ធរងចំនួន ៤ គឺ ១/-ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ (RFT) ២/-ប្រព័ន្ធទូទាត់ចល័ត (MPS) ៣/-ប្រព័ន្ធទូទាត់តាម QR (QPS) និង ៤/-ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក (ECS) ដែលក្នុងចំណោមប្រព័ន្ធទាំង ៤ មានតែប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ និងប្រព័ន្ធផាត់ទាត់អេឡិចត្រូនិកប៉ុណ្ណោះដែលបានដាក់ឱ្យប្រើប្រាស់ ចំណែកប្រព័ន្ធផ្សេងទៀតកំពុងស្ថិតក្នុងដំណាក់កាលធ្វើសន្ទានកម្ម។

គិតត្រឹមឆ្នាំ២០២៣ ប្រព័ន្ធរីផែលផេមានគ្រឹះស្ថានសមាជិកសរុបចំនួន ២៤ គ្រឹះស្ថាន ដែលក្នុងនោះមានគ្រឹះស្ថានចំនួន ១៦ បានដាក់ឱ្យដំណើរការប្រព័ន្ធរីផែលផេជាសាធារណៈតាមគ្រប់បណ្តាញប្រតិបត្តិការរបស់ខ្លួនដែលរួមមាន ការធ្វើប្រតិបត្តិការតាមបញ្ជររបស់គ្រឹះស្ថាន និងតាមបណ្តាញសេវាធនាគារចល័តរបស់ខ្លួន ដោយអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរមូលនិធិអន្តរធនាគាររវាងគ្រឹះស្ថានជាសមាជិកបានប្រកបដោយភាពងាយស្រួល រហ័ស សុវត្ថិភាព និងប្រសិទ្ធភាព។

ក្នុងឆ្នាំ២០២៣ ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT ជាប្រាក់រៀល មានចំនួន ១៦.៥៦៦ ប្រតិបត្តិការ (ថយចុះ ៣៧,៩%) និងមានទំហំប្រាក់ ៨៣៩.០៨០ លានរៀល (ថយចុះ ៥,៥%)។ រីឯ ចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៤៥.៨៨៦ ប្រតិបត្តិការ (ថយចុះ ១,៩%) និងមានទំហំប្រាក់ ២១១,៧៤ លានដុល្លារអាមេរិក (ថយចុះ ១១,៩%)។ ទំហំប្រាក់សរុបធ្វើប្រតិបត្តិការតាមប្រព័ន្ធរីផែលផេនៅក្នុងឆ្នាំ២០២៣ មានទំហំប្រមាណ ១% នៃផ.ស.ស។

**ក្រាហ្វ ១១ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិក តាមប្រព័ន្ធ RFT**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០២៣ ប្រព័ន្ធបាគងជាប្រព័ន្ធទូទាត់ដែលពេញនិយមដោយមានការប្រើប្រាស់ច្រើនជាងប្រព័ន្ធទូទាត់ផ្សេងៗទៀត បើផ្អែកលើចំនួនប្រតិបត្តិការ។ រីឯ ប្រព័ន្ធធនាគារអនឡាញនៅតែជាប្រព័ន្ធដែលមានទំហំប្រាក់ប្រតិបត្តិការទូទាត់ច្រើនជាងប្រព័ន្ធទូទាត់ផ្សេងៗទៀត ដូចមានបង្ហាញក្នុងក្រាហ្វខាងក្រោម៖

**ក្រាហ្វ ១២ - ចំនួន និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣.២. ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់

ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ ត្រូវបានអនុវត្តឡើងក្នុងគោលបំណងកាត់បន្ថយហានិភ័យចម្បងៗដែលអាចកើតមានក្នុងប្រព័ន្ធទូទាត់ដូចជា ហានិភ័យសន្ទនីយភាព ហានិភ័យទូទាត់ ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធ។

### ក). ការគ្រប់គ្រងហានិភ័យសន្ទនីយភាព ហានិភ័យទូទាត់ និងហានិភ័យឥណទាន

ដើម្បីបង្ការនូវហានិភ័យក្នុងប្រព័ន្ធផាត់ទាត់ជាតិ ធនាគារជាតិនៃកម្ពុជាបានរៀបចំយន្តការដោះស្រាយ និងគ្រប់គ្រង ដូចខាងក្រោម៖

- រៀបចំប្រព័ន្ធតាមដានសន្ទនីយភាព ដើម្បីអនុញ្ញាតឱ្យសមាជិកនីមួយៗអាចពិនិត្យមើលសមតុល្យមូលនិធិដែលមានក្នុងគណនីទូទាត់ជាប្រចាំ

- ផ្តល់សន្ទនីយភាពក្នុងថ្ងៃដល់សមាជិកដែលជួបប្រទះកង្វះខាតសាច់ប្រាក់ ក្នុងការទូទាត់ (ឥណទានវិបារូបន៍ដោយមានវត្ថុធានា)
- សមាជិកអាចស្នើសុំឥណទានវិបារូបន៍ស្មើនឹង ១០០% នៃតម្លៃប្រាតិភោគ
- ប្រសិនបើសមាជិកពុំមានសន្ទនីយភាពគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចទូទាត់សុទ្ធពហុភាគីរបស់ខ្លួនតាមពេលកំណត់ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជាអាចពន្យារពេលបិទការទូទាត់ ដើម្បីឱ្យសមាជិកដែលខ្វះសន្ទនីយភាពមានពេលវេលាបន្ថែមក្នុងការសម្របសម្រួលរកសន្ទនីយភាពពីប្រភពផ្សេងៗសម្រាប់បំពេញកាតព្វកិច្ចទូទាត់សុទ្ធ។ ក្នុងករណីនេះ សមាជិកនោះនឹងត្រូវរងពិន័យក្នុងការបណ្តាលឱ្យមានការពន្យារពេលការទូទាត់
- ការផាត់ទាត់ឡើងវិញ (Unwinding of Clearing) ជាមធ្យោបាយចុងក្រោយ ដែលអាចត្រូវបានអនុវត្តនៅពេលដែលសមាជិកផ្ទាល់ណាមួយគ្មានលទ្ធភាពរកសន្ទនីយភាពសម្រាប់បំពេញកាតព្វកិច្ចទូទាត់បានទាន់ពេលវេលា។ ប្រសិនបើមានករណីនេះកើតឡើង ការផាត់ទាត់ត្រូវធ្វើឡើងវិញ ហើយរាល់អ៊ីនភុតឧបករណ៍ដែលត្រូវទូទាត់របស់សមាជិកទាំងអស់ត្រូវបញ្ជូនជាថ្មីមកសភាផាត់ទាត់ជាតិ ដើម្បីដំណើរការផាត់ទាត់ និងទូទាត់ឡើងវិញ លើកលែងតែឧបករណ៍ទូទាត់របស់សមាជិកដែលគ្មានលទ្ធភាពទូទាត់សងត្រូវបានដកចេញទាំងអស់
- ពិដានឥណពន្ធសុទ្ធ (Net Debit Cap)៖ ប្រព័ន្ធគ្រប់គ្រងពិដានឥណពន្ធសុទ្ធ រក្សាបរិមាណពិដានឥណពន្ធសុទ្ធសម្រាប់ប្រព័ន្ធរីធែលជេ
- ការទូទាត់សងនៃ Loss sharing៖ សមាជិកដែលខកខានក្នុងការទូទាត់សុទ្ធ ត្រូវទូទាត់សងចំនួនប្រាក់ដែលសមាជិកដទៃទៀតបានរួមចំណែក ដោយបូកបន្ថែមការប្រាក់ដែលត្រូវគិតតាមអត្រាឥណទានវិបារូបន៍របស់ធនាគារជាតិនៃកម្ពុជា នៃការប្រាក់លើបំណុលនិងអប្បហារ
- បញ្ចូលឈ្មោះអតិថិជនដែលចេញមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ទៅកាន់ប្រព័ន្ធរបស់ការិយាល័យឥណទានកម្ពុជា (CBC)។

### ខ). ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធ

ដើម្បីគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធក្នុងប្រព័ន្ធផាត់ទាត់ជាតិឱ្យដំណើរការប្រតិបត្តិការដោយរលូន ធនាគារជាតិនៃកម្ពុជាបានរៀបចំយន្តការគ្រប់គ្រងដូចជា រៀបចំប្រព័ន្ធសម្រាប់សង្គ្រោះទិន្នន័យពេញលេញដែលបានបំពាក់នៅស្នាក់ការកណ្តាលនៃធនាគារជាតិនៃកម្ពុជា និងនៅមណ្ឌលសង្គ្រោះ។ ប្រព័ន្ធសង្គ្រោះទិន្នន័យនៅស្នាក់ការកណ្តាលមានសមត្ថភាពបច្ចេកទេសរឹងមាំធន់នឹងគ្រោះមហន្តរាយជាអតិបរមា ដែលអាចធានាការស្រោចស្រង់ទិន្នន័យបានភ្លាមៗដោយស្វ័យប្រវត្តិ និងអាចដំណើរការវិញក្នុងរយៈពេលមួយម៉ោង។ ទន្ទឹមនឹងនោះ ក្នុងករណីមានភាពរអាក់រអួលនៃប្រព័ន្ធប្រតិបត្តិការរបស់សមាជិកណាមួយ ធនាគារជាតិនៃកម្ពុជាផ្តល់យន្តការសម្រួលភ្លាមៗនៅនឹងកន្លែងជា Back-Up Bureau Services ចំពោះសមាជិកណាដែលមិនអាចបញ្ជូនទិន្នន័យជា

អេឡិចត្រូនិកមកសភាផាត់ទាត់ជាតិបានដោយសារបញ្ហាផ្នែកបច្ចេកទេស។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំជា Secondary site ដោយបំពាក់ឧបករណ៍កុំព្យូទ័រ Software និង Hardware ក្នុងករណីមានករណីប្រធានសក្តិ ឬជំងឺឆ្លងដែលមិនអាចចូលមកកន្លែងធ្វើការបាន។ វិធានការការពារការវាយប្រហារសាយប័រ ក៏ត្រូវបានពង្រឹងតាមរយៈកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការវាយប្រហារតាមអ៊ីនធឺណិត នាយកដ្ឋានព័ត៌មានវិទ្យានៃធនាគារជាតិនៃកម្ពុជាបានធ្វើបច្ចុប្បន្នភាពកម្មវិធីការពារសុវត្ថិភាពជាប្រចាំ ដោយធ្វើការកែលម្អប្រព័ន្ធសុវត្ថិភាព រៀបចំបណ្តុះបណ្តាលជាប្រចាំលើសុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យាដែលរួមមាន ការវាយប្រហារតាមអ៊ីនធឺណិតថ្មីៗនិងវិធានការការពារ និងរៀបចំឱ្យមានក្រុមការងារសម្រាប់ត្រួតពិនិត្យនិងទប់ស្កាត់ការវាយប្រហារតាមអ៊ីនធឺណិតដែលអាចកើតមានឡើង។

ក្នុងឆ្នាំ២០២៣ ទោះបីជាបានជួបបញ្ហារអាក់រអួលផ្នែកបច្ចេកទេសខ្លះៗដែលបណ្តាលមកពីដាច់បណ្តាញប្រព័ន្ធ មិនអាចទំនាក់ទំនងជាមួយប្រព័ន្ធធនាគារស្នូលបានក៏ដោយ ប៉ុន្តែបញ្ហានេះត្រូវបានដោះស្រាយភ្លាមៗទាន់ពេលវេលា។ ដោយឡែក ចំពោះការពន្យារពេលទូទាត់ដោយមូលហេតុកង្វះសន្ទនីយភាពពុំធ្លាប់ជួបប្រទះឡើយ ដោយសារសមាជិកនីមួយៗបានយកចិត្តទុកដាក់ក្នុងការពិនិត្យតាមដានសមតុល្យនៅក្នុងគណនីទូទាត់ ដើម្បីធានាថាមានមូលនិធិគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចទូទាត់នៅក្នុងថ្ងៃ។ ជារួម ប្រព័ន្ធផាត់ទាត់ជាតិបានដំណើរការដោយរលូន ដែលបច្ចុប្បន្នប្រព័ន្ធនេះអាចរក្សាបាននូវការអនុវត្តសម្រេចបានកម្រិតស្តង់ដារបច្ចេកទេស ៩៥% នៃរង្វាស់គោល ១០០%។ ការអនុវត្តប្រចាំថ្ងៃត្រូវបានគណនាដោយធៀបនឹងកម្រិតគោលសម្រាប់ដំណើរការប្រចាំថ្ងៃដូចជា ពេលវេលាផាត់ទាត់និងទូទាត់ជាក់ស្តែង (៨០%) ពេលវេលាចាប់ផ្តើមជាក់ស្តែងក្នុងថ្ងៃ (៥%) ម៉ោងឈប់ទទួល Input (៥%) ពេលវេលាទូទាត់ជាក់ស្តែង (៥%) ព្រមទាំងបញ្ហាផ្សេងៗនៃកិច្ចដំណើរការជាក់ស្តែងដែលកើតឡើងដោយសារការធ្វើបច្ចុប្បន្នកម្ម និងការផ្លាស់ប្តូរកម្មវិធី (៥%)។

## ៣.៣. ស្តង់ដារឧបករណ៍ និងបណ្តាញប្រព័ន្ធទូទាត់សងប្រាក់

ការអនុវត្តស្តង់ដាររួមស្របតាមនវានុវត្តន៍អន្តរជាតិនឹងសម្រួលដល់ការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់សងប្រាក់ទាំងក្នុងស្រុក និងក្នុងតំបន់។ ម្យ៉ាងវិញទៀត ការដាក់ឱ្យប្រើប្រាស់ស្តង់ដាររួមនេះ អាចការពារអតិថិជនទាក់ទងនឹងការក្លែងបន្លំ និងផ្តល់លទ្ធភាពក្នុងការធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថាន។

- **ស្តង់ដារលេខអត្តសញ្ញាណធនាគារ**

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលមានប្រសិទ្ធភាពដើម្បីឆ្លើយតបនឹងតម្រូវការសាធារណជន និងដើម្បីគាំទ្រដល់ការរីកចម្រើនសេដ្ឋកិច្ចជារួម។ ក្នុងន័យនេះ ក្នុងគោលបំណងលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផាត់ទាត់ជាតិលើឧបករណ៍មូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី ការកំណត់លេខអត្តសញ្ញាណធនាគារ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ ដែលជាស្តង់ដារ

លេខអត្តសញ្ញាណធនាគារប្រើប្រាស់សម្រាប់សម្គាល់គ្រឹះស្ថានធនាគារ និងសាខាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលជាសមាជិកប្រព័ន្ធផាត់ទាត់ជាតិ។

- **មូលប្បទានបត្រស្តង់ដារ**

ក្នុងគោលបំណងឱ្យមានការឯកភាពជាលក្ខណៈស្តង់ដារនូវមូលប្បទានបត្រដែលប្រើប្រាស់ក្នុងប្រព័ន្ធធនាគារ និងដើម្បីឱ្យការទូទាត់និងផាត់ទាត់អន្តរធនាគារប្រព្រឹត្តទៅដោយពិលាស និងមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសស្តីពី មូលប្បទានបត្រស្តង់ដារ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨។ ប្រកាសនេះក៏មានភ្ជាប់ជាមួយនូវសេចក្តីណែនាំស្តីពី លក្ខណៈស្តង់ដារនៃមូលប្បទានបត្រដែលជាឧបសម្ព័ន្ធដោយបានកំណត់ពីទំហំមូលប្បទានបត្រ លេខកូត និទ្ទេស ព្រមទាំងមានចារឹកតួលេខ និងសញ្ញាពិសេសដែលអាចអានបានដោយម៉ាស៊ីន និងអនុសាសន៍លើការការពារការក្លែងបន្លំជាដើម។

- **គំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានជាអេឡិចត្រូនិក**

កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសស្តីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន ដែលជាគំរូលាយលក្ខណ៍អក្សរ ឬអេឡិចត្រូនិកសម្រាប់ការផ្ទេរប្រាក់ពីគណនីទៅគណនីជាអេឡិចត្រូនិក។

- **ការកំណត់ស្តង់ដារលេខអត្តសញ្ញាណធនាគារលើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក**

ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់លេខអត្តសញ្ញាណធនាគារ (BIN) ការអនុវត្តស្តង់ដារ និងឧត្តមានុវត្តអន្តរជាតិនៃការប្រើប្រាស់ប័ណ្ណឥណពន្ធរបស់ប្រព័ន្ធខេមបូខាន-ស៊ែស្វីច នៅប្រទេសកម្ពុជា កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងស្តីពី ការផ្អាកដំណើរការលេខអត្តសញ្ញាណធនាគារមិនមែនស្តង់ដារសម្រាប់ប័ណ្ណឥណពន្ធក្នុងស្រុករបស់ប្រព័ន្ធខេមបូខានស៊ែស្វីច ដោយមានគ្រឹះស្ថានមួយចំនួននៅបន្តប្រើប្រាស់ប័ណ្ណឥណពន្ធដែលមានលេខអត្តសញ្ញាណធនាគារមិនមែនស្តង់ដារស្របតាមវិធាន និងនីតិវិធីប្រព័ន្ធខេមបូខានស៊ែស្វីច ដែលធនាគារជាតិនៃកម្ពុជាបានកំណត់ស្តង់ដារអត្តសញ្ញាណធនាគារលើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក (៩១១៦)។

- **ការកំណត់ស្តង់ដារ Chip EMV សម្រាប់ប័ណ្ណទូទាត់ក្នុងស្រុក**

ដើម្បីលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពក្នុងប្រព័ន្ធខេមបូខានស៊ែស្វីច និងរក្សាជំនឿទុកចិត្ត និងការកាពារអតិថិជនលើការប្រើប្រាស់ប័ណ្ណទូទាត់ ធនាគារជាតិនៃកម្ពុជាបានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រើប្រាស់ស្តង់ដារ Chip EMV លើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុករបស់ខ្លួន តាមរយៈសេចក្តីជូនដំណឹងស្តីពី ការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធខេមបូខានស៊ែស្វីច ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

- **ការអនុវត្តគោលការណ៍សុវត្ថិភាពលើម៉ាស៊ីន ATM និង/ឬ POS**

ក្រៅពីការកំណត់ស្តង់ដារនៃឧបករណ៍ទូទាត់ ធនាគារជាតិនៃកម្ពុជាបានជំរុញគ្រប់គ្រឹះស្ថានសមាជិកប្រព័ន្ធខេមបូឆានស្វៃស៊្វីច ដែលដាក់ឱ្យដំណើរការម៉ាស៊ីន ATM និង/ឬ POS ត្រូវអនុវត្តគោលការណ៍សុវត្ថិភាពនៅលើម៉ាស៊ីន ATM និង/ឬ POS ដូចមានចែងក្នុងវិធាននិងនីតិវិធីប្រព័ន្ធខេមបូឆានស្វៃស៊្វីច ស្តីពី "គោលការណ៍សុវត្ថិភាពលេខសម្ងាត់ (PIN) និងទិន្នន័យប័ណ្ណ" រួមមាន (១) EPP shield and/or Anti-PIN pad Overlay (២) Anti-card Skimming (៣) Anti-card Trapping និង (៤) PCI-DSS compliance។

- **ខេអេចឃ្យូអរកូត (KHQR Code)**

ដើម្បីបង្កើនប្រសិទ្ធភាពទូទាត់ និងសណ្តាប់ធ្នាប់នៃការទូទាត់តាមឃ្យូអរកូត ជាពិសេសជំរុញការទូទាត់តាមឃ្យូអរកូតឆ្លងគ្រឹះស្ថាន ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូតសម្រាប់ការទូទាត់សងប្រាក់ កាលពីថ្ងៃ២៦ ខែមិថុនា ឆ្នាំ២០២០ និងបានជ្រើសរើសយកប្រព័ន្ធបាគងជាមជ្ឈមណ្ឌលទូទាត់ និងបានដាក់ឱ្យដំណើរការប្រើប្រាស់ស្តង់ដារខេអេចឃ្យូអរកូតជាផ្លូវការ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២។ បច្ចុប្បន្ន សមាជិកខេអេចឃ្យូអរកូតមានចំនួនសរុប ៥៨ គ្រឹះស្ថាន ដែលបានប្រើប្រាស់ខេអេចឃ្យូអរកូត។

- **ស្តង់ដារសារ ISO ២០០២២**

ធនាគារកណ្តាលនៃសហគមប្រទេសអាស៊ានបានសម្រេចជ្រើសយកស្តង់ដារសារ ISO ២០០២២ ជាស្តង់ដារសារសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុនៃប្រទេសជាសមាជិកអាស៊ាន។ បណ្តាធនាគារកណ្តាលនៃប្រទេសសហគមអាស៊ានត្រូវត្រៀមខ្លួនជាស្រេចសម្រាប់ស្តង់ដារ ISO ២០០២២ នេះ។ អនុលោមតាមនវានុវត្តន៍អន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានទទួល និងប្រើប្រាស់ស្តង់ដារសារ ISO ២០០២២ នេះទាំងប្រព័ន្ធទូទាត់រាយ និងប្រព័ន្ធទូទាត់តម្លៃធំ ដែលកំពុងអភិវឌ្ឍ។

## ប្រអប់ ៣ - វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០២៣

ធនាគារជាតិនៃកម្ពុជាសហការជាមួយសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា (CAFT) បានរៀបចំវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០២៣ (CamTech Summit 2023) ក្រោមទស្សនាទាន "ការបង្កើតទំនាក់ទំនង៖ ជំរុញកិច្ចសហប្រតិបត្តិការ និងនវានុវត្តន៍សេវាហិរញ្ញវត្ថុឌីជីថលក្នុងតំបន់មេគង្គ និងតំបន់ផ្សេងៗ"។ វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០២៣ នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ឱកាសដល់បញ្ញត្តិករ អ្នករៀបចំគោលនយោបាយ ជំនាញការ និងភាគីពាក់ព័ន្ធ សិក្សានិងចែករំលែកចំណេះដឹង បទពិសោធន៍ និងឧត្តមានុភាពស្តីពី ការរីកចម្រើននៃវិស័យបច្ចេកវិទ្យានៅក្នុងប្រទេសកម្ពុជា។

ការរៀបចំវេទិកានេះ នឹងផ្តល់លក្ខណៈអំណោយផលដល់បញ្ញត្តិករ និងភាគីពាក់ព័ន្ធក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុពិភាក្សាពីកាលានុវត្តភាព និងការអនុវត្តគោលនយោបាយផ្សេងៗ ព្រមទាំងបង្ហាញពីការរីកចម្រើននៃវិស័យបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា និងសកលលោក។ វេទិកានេះបានបញ្ជ្រាបនូវចំណេះដឹង និងព័ត៌មានកាន់តែស៊ីជម្រៅថែមទៀតដល់អ្នកចូលរួម តាមរយៈបទបង្ហាញ កិច្ចពិភាក្សា និងពិព័រណ៍ផ្សព្វផ្សាយផលិតផល និងសេវាបច្ចេកវិទ្យាហិរញ្ញវត្ថុនានាទាំងក្នុងនិងក្រៅប្រទេស។ ជារួម វេទិកានេះបានរួមចំណែកលើកកម្ពស់ការយល់ដឹង កិច្ចសហការ ចែករំលែកបទពិសោធន៍ក្នុងការរៀបចំគោលនយោបាយ និងបទប្បញ្ញត្តិ ឱ្យស្របតាមការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ឆ្ពោះទៅកាន់សេដ្ឋកិច្ច និងសង្គមឌីជីថល។



# ៤ ការគ្រប់គ្រងសេវាទូទាត់សងប្រាក់

## ៤.១. និន្នាការទូទៅ និងការវិវត្តន៍

សេវាទូទាត់សងប្រាក់នៅកម្ពុជាបានបន្តអភិវឌ្ឍដើម្បីឆ្លើយតបទៅនឹងតម្រូវការអតិថិជនលើការប្រើប្រាស់សេវាទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍ ងាយស្រួល សុវត្ថិភាព និងចំណាយទាប។ គិតត្រឹមឆ្នាំ២០២៣ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់សរុបមានចំនួន ៣៣ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ២ ទទួលបានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការទូទាត់សងប្រាក់ពីធនាគារជាតិនៃកម្ពុជា។

ប្រតិបត្តិការសេវាទូទាត់សងប្រាក់មានការកើនឡើងជាបន្តបន្ទាប់ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃអតិថិជនចុះឈ្មោះប្រើប្រាស់គណនីកាបូបអេឡិចត្រូនិក (E-wallet) និងបណ្តាញទូទាត់សងប្រាក់។ គិតត្រឹមឆ្នាំ២០២៣ ទិន្នន័យអតិថិជនចុះឈ្មោះបង្កើតគណនីកាបូបអេឡិចត្រូនិកសរុបមានចំនួន ១៩,៧ លានគណនី កើនឡើង ១,១% និងភ្នាក់ងារមានចំនួនសរុប ៦០,៥ ពាន់ទីតាំង ដែលមានការកើនឡើង ១៥,៧% ធៀបនឹងឆ្នាំ២០២២។ ចំណែកឯចំនួនប្រតិបត្តិការសរុបនៃសេវាទូទាត់ចល័តតាមកាបូបអេឡិចត្រូនិកនៅក្នុងឆ្នាំ២០២៣ មានការកើនឡើងប្រមាណ ២៨,៧% ពី ៤៦៧,៤ ទៅ ៦០១,៣ លានប្រតិបត្តិការ និងទំហំប្រាក់កើនឡើងប្រមាណ ១៨% ពី ៦៤,៣ ទៅ ៧៥,៨ ប៊ីលានដុល្លារអាមេរិក ធៀបនឹងឆ្នាំ២០២២ ប្រមាណ ២៣៦,៥% នៃផ.ស.ស។

**ក្រាហ្វ ១៣ - ចំនួនភ្នាក់ងារ អតិថិជនចុះឈ្មោះគណនី E-wallet និងអតិថិជន Walk-in របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៤ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័ត តាមកាបូបអេឡិចត្រូនិក (Mobile E-wallet)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ស្របនឹងកំណើននៃការប្រើប្រាស់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលផ្តល់សេវាទូទាត់ ក៏បានបន្តគ្រប់គ្រងមូលនិធិរបស់អតិថិជនបានល្អប្រសើរដើម្បីធានាផលប្រយោជន៍ដល់អ្នកប្រើប្រាស់ និងរក្សាទំនុកចិត្តរបស់សាធារណជនមកលើសេវាទូទាត់សងប្រាក់ តាមរយៈការគោរពតាមបទប្បញ្ញត្តិដែលតម្រូវឱ្យគ្រឹះស្ថានរក្សាបាននូវសមតុល្យក្នុងគណនីអាណត្តិព្យាបាល (Trust Account) បានខ្ពស់ជាងសមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ។ គិតត្រឹមចុងឆ្នាំ២០២៣ សមតុល្យប្រាក់សរុបដែលបានរក្សាទុកក្នុងគណនីអាណត្តិព្យាបាលមានចំនួន ៤៤៣ លានដុល្លារអាមេរិក និងសមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយមានចំនួន ៤៣៨,៧ លានដុល្លារអាមេរិក។

**ក្រាហ្វ ១៥ - សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទន្ទឹមនេះ ចំពោះសេវាធនាគារអេឡិចត្រូនិកមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៨ បានផ្តល់សេវាធនាគារអ៊ីនធឺណិត និងគ្រឹះស្ថានចំនួន ៣៧ ផ្តល់សេវាធនាគារចល័ត ក្នុងនោះចំនួនប្រតិបត្តិការតាមរយៈសេវាធនាគារអ៊ីនធឺណិតក្នុងឆ្នាំ២០២៣ មានការកើនឡើងប្រមាណ ៤២,៦% ពី ៣,៣ ទៅ ៤,៧ លានប្រតិបត្តិការ ក្នុងទំហំប្រាក់ ១៨,២ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៥៦,២% នៃផ.ស.ស។ ចំណែកឯ ចំនួនប្រតិបត្តិការរបស់សេវាធនាគារចល័តមានការកើនឡើងប្រមាណ ៦០,៧% ពី ៤៨៥,១ ទៅ ៧៧៩,៥ លានប្រតិបត្តិការ និងទំហំប្រាក់មានការកើនឡើងប្រមាណ ១០,៦% ពី ១៦៤,៧ ទៅ ១៨២,២ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៥៦៨,១% នៃផ.ស.ស។

**ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការរបស់សេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប័ណ្ណទូទាត់នៅតែបន្តពេញនិយមក្នុងការប្រើប្រាស់ជំនួសសាច់ប្រាក់ ក្នុងនោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលបានចេញផ្សាយប័ណ្ណទូទាត់មានចំនួន ៤១ គ្រឹះស្ថាន និងបានចេញផ្សាយប័ណ្ណទូទាត់សរុបប្រមាណ ១៣,១ លានប័ណ្ណ។ ក្នុងឆ្នាំ២០២៣ ប្រតិបត្តិការទូទាត់តាមប័ណ្ណទូទាត់ជារូបវន្តក្នុងស្រុកសរុប មានការកើនឡើងប្រមាណ ៥៣,៣% ពី ៩៨,៣ ទៅ ១៥០,៧ លានប្រតិបត្តិការ និងទំហំប្រាក់កើនឡើងប្រមាណ ៣២% ពី ២២,៥ ទៅ ២៩,៧ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៩២,៥% នៃផ.ស.ស។

ដោយឡែក ចំនួនប្រតិបត្តិការប័ណ្ណទូទាត់ជារូបវន្តនៅក្រៅប្រទេសមានការកើនឡើងប្រមាណ ២៦,៧% ពី ២,២ ទៅ ២,៨ លានប្រតិបត្តិការ និងទំហំប្រាក់កើនឡើងប្រមាណ ១៤,៦% ពី ០,៩៦ ទៅ ១,១ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៣,៤% នៃផ.ស.ស។ ចំណែកឯប្រតិបត្តិការប័ណ្ណទូទាត់តាមអនឡាញសរុបមានការកើនឡើងប្រមាណ ៤៥% ពី ១៩,២ ទៅ ២៧,៩ លានប្រតិបត្តិការ និងទំហំប្រាក់មានការកើនឡើងប្រមាណ ៥៤,៨% ពី ០,៧ ទៅ ១ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៣,២% នៃផ.ស.ស។ ស្របគ្នានេះដែរ មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៤១ គ្រឹះស្ថាន បានតម្លើងម៉ាស៊ីនដាក់/ដកប្រាក់ចំនួន ៥,៤ ពាន់គ្រឿង និង ៣២ គ្រឹះស្ថានបានតម្លើងម៉ាស៊ីនឆូតកាតចំនួន ៥២,១ ពាន់គ្រឿង នៅទូទាំងប្រទេសកម្ពុជា។

**ក្រាហ្វ ១៧ - ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងប័ណ្ណទូទាត់អន្តរជាតិ)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៨ - ចំនួនម៉ាស៊ីន ATM និងម៉ាស៊ីន POS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ជាមួយគ្នានេះ ការដាក់ឱ្យប្រើប្រាស់ស្តង់ដារខេអេចឃ្យូអរកូតដែលជួយសម្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថានបានធ្វើឱ្យការទូទាត់សងប្រាក់តាមឃ្យូអរកូតកាន់តែមានការពេញនិយមប្រើប្រាស់ក្នុងការទូទាត់បែបអេឡិចត្រូនិកជំនួសឱ្យការទូទាត់ជាសាច់ប្រាក់។ ការណ៍នេះ ធ្វើឱ្យអតិថិជនកាន់តែមានទំនុកចិត្តក្នុងការប្រើប្រាស់ និងទទួលបានបទពិសោធន៍ថ្មីពីសេវាទូទាត់តាមឃ្យូអរកូតនេះ។ ក្នុងឆ្នាំ២០២៣ ចំនួនប្រតិបត្តិការទូទាត់តាមឃ្យូអរកូតមានការកើនឡើងជាលំដាប់ ដោយប្រតិបត្តិការមានចំនួនប្រមាណ ១៧៨ លានប្រតិបត្តិការ កើនឡើង ៦៦៤,២% ធៀបនឹងឆ្នាំ២០២២ ស្មើនឹងទំហំប្រាក់សរុបចំនួន ២៣,៥ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៧៣,៩% នៃផ.ស.ស។

**ក្រាហ្វ ១៩ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR Code**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤.២. ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ដើម្បីធានាបាននូវស្ថិរភាព និរន្តរភាព កាត់បន្ថយហានិភ័យជាប្រព័ន្ធ ការពារផលប្រយោជន៍អតិថិជន ជំរុញការប្រកួតប្រជែង និងជំរុញការប្រើប្រាស់សេវាទូទាត់ជាអេឡិចត្រូនិក ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ឱ្យស្របនឹងការរីកចម្រើននៃសេវាទូទាត់ថ្មីៗ ធនាគារជាតិនៃកម្ពុជាដែលមានតួនាទីត្រួតពិនិត្យ និងគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ អភិវឌ្ឍ និងរៀបចំបទប្បញ្ញត្តិឱ្យស្របនឹងការវិវត្តន៍ឥតឈប់ឈរនៃបច្ចេកវិទ្យា និងកំណើននៃការប្រើប្រាស់សេវាទូទាត់សងប្រាក់នៅកម្ពុជា។

សេវាទូទាត់សងប្រាក់លើសពីការប្រើប្រាស់ក្នុងប្រទេសកម្ពុជា ដែលបច្ចុប្បន្ននេះតម្រូវការនៃការប្រើប្រាស់សេវាទូទាត់សងប្រាក់ដើម្បីធ្វើប្រតិបត្តិការផ្ទេរប្រាក់ចូល និងផ្ទេរប្រាក់ចេញក្រៅប្រទេស

ក៏កំពុងមានការប្រើប្រាស់យ៉ាងទូលំទូលាយផងដែរ។ ដូចនេះ នៅដើមឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំស្តីពី "ការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់កិច្ចសហការផ្ទេរប្រាក់អន្តរជាតិ ក្នុងដំណាក់កាលសាកល្បង" ដើម្បីគ្រប់គ្រងលំហូរសាច់ប្រាក់ចេញ និងចូលប្រទេសកម្ពុជា ក៏ដូចជាទប់ស្កាត់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាដើម។ ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់សងប្រាក់ដែលធនាគារជាតិនៃកម្ពុជាបានអនុម័តកន្លងមក មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ១។

ក្នុងគោលបំណងធានាស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ និងលើកកម្ពស់នវានុវត្តន៍ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិថ្មីៗបន្ថែមទៀត ដូចជាការកំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការគ្រប់គ្រងគណនីអាណត្តិព្យាបាល នីតិវិធីត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការនិងប្រតិបត្តិករទីផ្សារឥណទានតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៤.៣. ការវិភាគ និងវាយតម្លៃសុខុមាលភាពគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជាមានតួនាទីត្រួតពិនិត្យ និងតាមដានជាប្រចាំទៅលើសុខុមាលភាពរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីធានាសុវត្ថិភាព និងបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើសេវាទូទាត់សងប្រាក់។ តាមរយៈនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញយន្តការត្រួតពិនិត្យជាប្រចាំលើគ្រឹះស្ថានដែលទទួលបានអាជ្ញាប័ណ្ណ ដោយអនុវត្តតាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ និងការវិភាគទៅពេលខាងមុខ (Risk-Based & Forward Looking Approach) ក៏ដូចជាការត្រួតពិនិត្យលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ (Compliance-Based Approach) សំដៅកាត់បន្ថយហានិភ័យ និងធានាបានសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ការត្រួតពិនិត្យផ្តោតជាសំខាន់ទៅលើសូចនាករចម្បងៗមានដូចខាងក្រោម៖

- **អភិបាលកិច្ច និងការត្រួតពិនិត្យផ្ទៃក្នុង៖** ការវាយតម្លៃនេះមានគោលបំណងពិនិត្យទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ជាពិសេសទៅលើការដាក់ចេញនូវគោលនយោបាយសំខាន់ៗសម្រាប់ដំណើរការគ្រឹះស្ថាន ការគ្រប់គ្រងហានិភ័យ ការអនុវត្តតាមបទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗរបស់ធនាគារជាតិនៃកម្ពុជា។
- **ហានិភ័យឥណទាន៖** ការវាយតម្លៃនេះមានគោលបំណងពិនិត្យអំពីប្រសិទ្ធភាពនៃការដាក់ចេញគោលការណ៍ និងនីតិវិធីចាំបាច់ក្នុងការគ្រប់គ្រងហានិភ័យឥណទាន ក៏ដូចជាការអនុវត្តជាក់ស្តែង ជាពិសេសចំពោះការគ្រប់គ្រង និងរក្សាសុវត្ថិភាពគណនីអាណត្តិព្យាបាលដែលមូលនិធិរបស់អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់។

- **ហានិភ័យសន្ទនីយភាព៖** ការវាយតម្លៃនេះមានគោលបំណងពិនិត្យអំពីប្រសិទ្ធភាពនៃការផ្ទៀងផ្ទាត់រវាងគណនីអាណាត្តិព្យាបាល និងគណនីរូបិយវត្ថុអេឡិចត្រូនិក ដើម្បីធានាគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មានសន្ទនីយភាពគ្រប់គ្រាន់។
- **ហានិភ័យប្រតិបត្តិការ៖** ជាការវាយតម្លៃមានគោលបំណងពិនិត្យទៅលើការគ្រប់គ្រងហានិភ័យសំខាន់ៗរួមមាន ប្រព័ន្ធសុវត្ថិភាពព័ត៌មានវិទ្យា ការរក្សាទុកនិងដំណើរការទិន្នន័យ ការទប់ស្កាត់ប្រតិបត្តិការក្លែងបន្លំ និងការវាយប្រហារសាយប័រ (Cyber-Attack) ជាដើម ដែលករណីទាំងនេះអាចបង្កផលប៉ះពាល់ជាអវិជ្ជមានមកលើប្រតិបត្តិការទូទាត់សងប្រាក់។
- **ហានិភ័យការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម៖** ការវាយតម្លៃនេះមានគោលបំណងពិនិត្យទៅលើការដាក់ចេញនូវគោលនយោបាយ និងយន្តការរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ក្នុងការទប់ស្កាត់នូវប្រតិបត្តិការសង្ស័យអំពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ជាពិសេសទៅលើប្រព័ន្ធសម្រាប់សម្គាល់អត្តសញ្ញាណអតិថិជនអេឡិចត្រូនិក និងតាមដាន កត់ត្រា និងរាយការណ៍ឱ្យមានប្រសិទ្ធភាព។
- **យន្តការការពារផលប្រយោជន៍អតិថិជន៖** ការវាយតម្លៃនេះមានគោលបំណងពិនិត្យទៅលើការដាក់ចេញគោលការណ៍ និងយន្តការសំខាន់ៗ ក្នុងការការពារផលប្រយោជន៍អតិថិជនតាមរយៈការបង្ហាញព័ត៌មានចាំបាច់ ខចែងនិងលក្ខន្តិកៈអំពីសេវាទូទាត់សងប្រាក់ ដែលអាចឱ្យអ្នកប្រើប្រាស់ងាយយល់មុននឹងប្រើប្រាស់។ លើសពីនេះ ការវាយតម្លៃក៏អនុវត្តទៅលើការដាក់ចេញនូវវិធីសាស្ត្រ និងនីតិវិធីអំពីការដោះស្រាយបណ្តឹងជូនអតិថិជនផងដែរ។
- **លទ្ធភាពស្វែងរកប្រាក់ចំណេញ៖** ការវាយតម្លៃនេះមានគោលបំណងពិនិត្យអំពីលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណេញពីប្រតិបត្តិការទូទាត់សងប្រាក់របស់គ្រឹះស្ថាន តាមរយៈការដាក់ចេញនូវផលិតផល ឬសេវាថ្មីៗប្រកបដោយភាពច្នៃប្រឌិត ដើម្បីទាក់ទាញការប្រើប្រាស់ពីអតិថិជន។
- **ភាពគ្រប់គ្រាន់នៃដើមទុន៖** ការវាយតម្លៃនេះមានគោលបំណងពិនិត្យទៅលើភាពរឹងមាំនៃគណនីដើមទុន និងស្ថិរភាពផ្នែកហិរញ្ញវត្ថុរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ភាពគ្រប់គ្រាន់នៃគណនីដើមទុនអាចនឹងជួយឱ្យគ្រឹះស្ថានអាចទប់ស្កាត់នូវការខាតបង់ផ្នែកគណនេយ្យ និងធានានិរន្តរភាពប្រតិបត្តិការ ដែលនឹងផ្តល់ជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់មកលើគ្រឹះស្ថាន។

## ៤.៤. ការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជាបានធ្វើការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ជាប្រចាំតាមរយៈការប្រមូលនូវរបាយការណ៍ប្រតិបត្តិការជាប្រចាំខែ និងប្រចាំឆ្នាំ រួចចងក្រងជាទិន្នន័យដើម្បីធ្វើការវិភាគ និងវាយតម្លៃសុខុមាលភាពរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ក្រៅពីនេះ

ធនាគារជាតិនៃកម្ពុជា ក៏បានដាក់ចេញនូវយន្តការត្រួតពិនិត្យដល់កន្លែងស្របតាមផែនការជាប្រចាំ នៅតាមទីស្នាក់ការកណ្តាល សាខា ឬទីតាំងពាក់ព័ន្ធផ្សេងៗរួមមានដូចជា ភ្នាក់ងារផ្តល់សេវាទូទាត់សងប្រាក់ និងពាណិជ្ជករទូទាត់រាយនៅតាមបណ្តាខេត្ត-ក្រុង ដើម្បីទទួលបានព័ត៌មាន និងទិដ្ឋភាពជាក់ស្តែង។ លើសពីនេះ ស្របតាមសេចក្តីណែនាំស្តីពី "ការជ្រើសរើស និងការទទួលស្គាល់សវនករគណនេយ្យឯករាជ្យចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់" ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យគ្រប់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ជ្រើសតាំងសវនករគណនេយ្យធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុជាប្រចាំឆ្នាំ ដើម្បីធានាពីសុក្រឹត្យភាព និងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបោះផ្សាយជាសាធារណៈ និងផ្ញើជូនធនាគារជាតិនៃកម្ពុជា។

# ៥ ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន

## ៥.១. កិច្ចសហប្រតិបត្តិការទ្វេភាគី លើគម្រោងផ្ទេរប្រាក់ និងការទូទាត់ឆ្លងដែន

ការទូទាត់និងផ្ទេរប្រាក់ឆ្លងដែន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងពិភពលោក និងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជំរុញវិស័យទេសចរណ៍ ព្រមទាំងរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការផ្តល់ជាមធ្យោបាយសម្រួលដល់ការផ្ទេរប្រាក់និងទូទាត់ទំនិញ ដែលមានកម្រៃទាបសម្រាប់ពលករចំណាកស្រុក និងអ្នកធុរកិច្ច។ ក្នុងគោលបំណងពង្រឹងកិច្ចសហការលើការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ ប្រតិបត្តិការទូទាត់សងប្រាក់និងផ្ទេរប្រាក់ឆ្លងដែនប្រកបដោយបរិយាបន្ន និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែននេះជាមួយប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី និងក្រុមហ៊ុនអន្តរជាតិយូញៀនផេ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តពង្រីកគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសផ្សេងទៀតក្នុងតំបន់ និងដៃគូសហការនានា ដូចជាប្រទេសចិន ជប៉ុន ឥណ្ឌា សិង្ហបុរី និងក្រុមហ៊ុនអាលីផេ (Alipay Connect Pte. Ltd.)។ ក្រៅពីគម្រោងទូទាត់ឆ្លងដែនខាងលើ ធនាគារជាតិនៃកម្ពុជាក៏បានពង្រឹងកិច្ចសហប្រតិបត្តិការ និងចុះអនុស្សរណៈយោគយល់គ្នាលើផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ជាមួយប្រទេសចំនួនបីផ្សេងទៀត រួមមាន ប្រទេសរវ៉ាន់ដា ហ្វ៊ីជី និងកោះសូឡូម៉ូន។



- គម្រោងកិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនតាមឃ្យូអរកូតរវាងប្រទេសកម្ពុជា និងប្រទេសថៃ បានដាក់ឱ្យដំណើរការដោយជោគជ័យនូវដំណាក់កាលទី១ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ និងដំណាក់កាលទី២ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣ កន្លងទៅ។ គម្រោងទូទាត់នេះ អនុញ្ញាតឱ្យប្រជាជនរបស់ប្រទេសទាំងពីរអាចទូទាត់គ្នាទៅវិញទៅមកតាមឃ្យូអរកូតបានយ៉ាងងាយស្រួល និងសុវត្ថិភាព។ បន្ទាប់ពីដាក់ដំណើរការគម្រោងទូទាត់ឆ្លងដែននេះជោគជ័យរួចមក ជំហានបន្ទាប់ក្រុមការងារបច្ចេកទេសរបស់ធនាគារកណ្តាលទាំងពីរនឹងសិក្សារៀបចំអភិវឌ្ឍន៍គម្រោងផ្ទេរប្រាក់ឆ្លងដែន ដែលនឹងផ្តល់លទ្ធភាពសម្រួលដល់ពលករក្នុងការផ្ទេរប្រាក់ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងតម្លៃសមរម្យ។



- គម្រោងផ្ទេរប្រាក់ឆ្លងដែនរវាងប្រព័ន្ធបាគងជាមួយធនាគារមេយប៊ែង បានដាក់ឱ្យដំណើរការកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១។ គម្រោងនេះ នឹងជួយសម្រួលពលករចំណាកស្រុកដែលធ្វើការនៅប្រទេសម៉ាឡេស៊ី ផ្ទេរប្រាក់មកក្រុមគ្រួសារកាន់តែងាយស្រួល និងមានកម្រៃសេវាសមរម្យ។ បន្ទាប់ពីដាក់ឱ្យដំណើរការ សេវានេះនឹងរំពឹងថាផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាដែលកំពុងរស់នៅប្រទេសម៉ាឡេស៊ី និងប្រជាជនម៉ាឡេស៊ីដែលកំពុងរស់នៅប្រទេសកម្ពុជា ក៏ដូចជាធុរកិច្ចក្នុងប្រទេសទាំងពីរ ដោយប្រើប្រាស់អ៊ីវ៉ាឡេតរបស់ប្រព័ន្ធបាគង និងផ្លេតហ្វមឌីជីថលមេយប៊ែងធូយូ ដើម្បីផ្ទេរមូលនិធិឆ្លងប្រទេស សម្រាប់ការទូទាត់ពាណិជ្ជកម្ម និងការផ្ទេរប្រាក់។ កិច្ចសហប្រតិបត្តិការនេះនឹងជួយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងកិច្ចគាំទ្រចំពោះការវិវឌ្ឍន៍ទៅរកសង្គមឌីជីថលក្នុងប្រទេសកម្ពុជា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាកំពុងពិនិត្យលទ្ធភាពអភិវឌ្ឍការទូទាត់តាមឃ្យូអរកូតរវាងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី ដើម្បីជំរុញការទូទាត់ឌីជីថល និងគាំទ្រដល់វិស័យទេសចរណ៍ និងធុរកិច្ចរវាងប្រទេសទាំងពីរ។

- គម្រោងទូទាត់ឆ្លងដែនតាមឃ្យូអរកូតរវាងប្រទេសកម្ពុជា និងប្រទេសឡាវ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ សម្រាប់អតិថិជនប្រទេសកម្ពុជាអាចធ្វើការទូទាត់ដោយការស្កេនឃ្យូអរកូតនៅប្រទេសឡាវ។ ចំពោះអតិថិជនប្រទេសឡាវអាចធ្វើការទូទាត់ដោយការស្កេនឃ្យូអរកូតនៅប្រទេសកម្ពុជា គ្រោងនឹងដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០២៤។



តាមរយៈកិច្ចសហការនេះ ក៏បានដើរទន្ទឹមនឹងគោលបំណងនៃសហគមអាស៊ាន ក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិក្នុងទីផ្សារ និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ ពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចកាន់តែជិតស្និទ្ធរវាងប្រទេសកម្ពុជា និងប្រទេសឡាវ ដែលនឹងគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ និងអាចឱ្យប្រទេសទាំងពីរឈានដល់កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុមួយកម្រិតក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីជាប្រយោជន៍ដល់ប្រជាជនក្នុងប្រទេសទាំងពីរ។



- គម្រោងទូទាត់ឆ្លងដែនតាមយូអរកូតរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣។ គម្រោងនេះបាន អនុញ្ញាតឱ្យអតិថិជនកម្ពុជាប្រើប្រាស់កម្មវិធីធនាគារចល័តធ្វើការទូទាត់ដោយស្កេនយូអរកូតនៅតាមពាណិជ្ជករទូទាត់រាយនៅប្រទេសវៀតណាម និងអតិថិជនវៀតណាមអាចធ្វើការទូទាត់ស្កេនខេអេចយូអរកូត ជាមួយពាណិជ្ជករទូទាត់រាយនៅក្នុងប្រទេសកម្ពុជាបានយ៉ាងងាយស្រួល និងសុវត្ថិភាព។ ការដាក់ឱ្យដំណើរការគម្រោងនេះនឹងជំរុញការទូទាត់ឌីជីថល ជួយលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិក្នុងទីផ្សារក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ច ទេសចរ និងពាណិជ្ជកម្មឆ្លងដែនរវាងប្រទេសទាំងពីរ។

- ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សរណៈយោគយល់ជាមួយស្ថាប័ន NPCI International Payments Limited (NIPL) ប្រទេសឥណ្ឌា កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ស្តីពី កិច្ចសហប្រតិបត្តិការលើការទូទាត់ និងការផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសឥណ្ឌា ដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើការទូទាត់ និងការផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសឥណ្ឌា។ គោលបំណងនៃការចុះអនុស្សរណៈយោគយល់នេះ ដើម្បីបង្កើតជាក្របខណ្ឌកិច្ចសហប្រតិបត្តិការសម្រាប់ប្រទេសទាំងពីរ ក្នុងការអភិវឌ្ឍការតភ្ជាប់ និងអន្តរប្រតិបត្តិការជាឌីជីថល គាំទ្រដល់ការទូទាត់និងការផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសទាំងពីរ។ ការចុះអនុស្សរណៈយោគយល់នេះ នឹងផ្តល់អត្ថប្រយោជន៍កាន់តែច្រើនដល់ប្រជាពលរដ្ឋនៃប្រទេសទាំងពីរ ក្នុងការប្រើប្រាស់បណ្តាញផ្លូវការសម្រាប់ធ្វើប្រតិបត្តិការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែនប្រកបដោយសុវត្ថិភាព ងាយស្រួល និងតម្លៃសមរម្យ។ បន្ទាប់ពីការចុះអនុស្សរណៈយោគយល់ ក្រុមការងារបច្ចេកទេសកំពុងសិក្សារៀបចំតភ្ជាប់ផ្នែកបច្ចេកទេស មុននឹងឈានទៅដល់ការដាក់ឱ្យប្រើប្រាស់គម្រោង។




- ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនអាលីផេ (Alipay Connect Pte. Ltd.) បានចុះអនុស្សរណៈយោគយល់ស្ដីពី "កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនតាមឃ្យូអរកូត" កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ឆ្នាំ២០២៣ នៅប្រទេសសិង្ហបុរី។ អនុស្សរណៈយោគយល់នេះមានគោល-បំណងលើកកម្ពស់ប្រតិបត្តិការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូតរវាងបណ្ដាញខេអេចឃ្យូអរកូតរបស់ប្រព័ន្ធបាគង និងបណ្ដាញឃ្យូអរកូតរបស់ Alipay។ តាមរយៈកិច្ចសហប្រតិបត្តិការនេះ អ្នកប្រើប្រាស់ប្រព័ន្ធបាគងអាចធ្វើការទូទាត់ជាមួយអាជីវករដែលប្រើប្រាស់បណ្ដាញ Alipay ចំនួន ៨៣ លាន នៅទូទាំងសកលលោក។ អតិថិជនរបស់ក្រុមហ៊ុន Alipay អាចស្កេនខេអេចឃ្យូអរកូត ដើម្បីទូទាត់ថ្លៃទំនិញ-សេវា ទៅឱ្យអាជីវករ ឬម្ចាស់ហាងលក់ទំនិញ-សេវា នៅប្រទេសកម្ពុជាដែលមានគណនីជាប្រាក់រៀលបាន។ គម្រោងទូទាត់ឆ្លងដែនតាមឃ្យូអរកូតនេះ បង្ហាញពីចក្ខុវិស័យពង្រីកវិសាលភាពប្រតិបត្តិការទូទាត់ឆ្លងដែនតាមឃ្យូអរកូតរបស់ប្រព័ន្ធបាគងឱ្យកាន់តែទូលំទូលាយ។ បច្ចុប្បន្ន គម្រោងទូទាត់ឆ្លងដែនជាមួយក្រុមហ៊ុន Alipay ស្ថិតក្នុងការសិក្សាលើការតភ្ជាប់ផ្នែកបច្ចេកទេស។

- ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្ដាលចិន បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្ដីពី កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។ អនុស្សរណៈយោគយល់នេះមានគោលបំណងជំរុញនវានុវត្តន៍ក្នុងវិស័យធនាគារ និងប្រព័ន្ធទូទាត់សងប្រាក់ លើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពប្រតិបត្តិការទូទាត់ឆ្លងដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន និងកសាងសមត្ថភាពក្នុងវិស័យធនាគារនៅកម្ពុជាដើម្បីឆ្លើយតបទៅនឹងកំណើននៃពាណិជ្ជកម្ម ការវិនិយោគ និងលំហូរហិរញ្ញវត្ថុទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន។




- ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន (METI) បានចុះអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការស្ដីពី ការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូត (Unified

QR Code-Based Payment) កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣។ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការនេះ រៀបចំឡើងក្រោមសហ-អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម** KISHIDA Fumio នាយករដ្ឋមន្ត្រីនៃប្រទេសជប៉ុន នៅក្នុងកិច្ចប្រជុំកំពូលកម្ពុជា-ជប៉ុន ដែលបានប្រព្រឹត្តិទៅនៅទីក្រុងតូក្យូ ប្រទេសជប៉ុន។ អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការនេះ រៀបចំឡើងក្នុងគោលបំណងកំណត់ក្របខណ្ឌជាក់លាក់សម្រាប់កិច្ចសហប្រតិបត្តិការលើកកម្ពស់សកម្មភាពប្រើប្រាស់ប្រព័ន្ធទូទាត់ឆ្លងដែនតាមយូអរកូតដ៏ងាយស្រួល សុវត្ថិភាព និងប្រសិទ្ធភាព ព្រមទាំងជួយសម្រួលចរាចររូបិយវត្ថុជាតិ ជំរុញវិស័យទេសចរណ៍រវាងប្រទេសទាំងពីរឱ្យកាន់តែមានសក្តានុពលថែមទៀត។



- ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនអន្តរជាតិយូញៀនផេ បានចុះអនុស្សរណៈយោគយល់ស្តីពី "កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់" កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ និងបានដាក់ឱ្យដំណើរការជាផ្លូវការនៃការទូទាត់ឆ្លងដែនតាមយូអរកូត នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣។ គម្រោងទូទាត់ឆ្លងដែនតាមរយៈយូអរកូតនេះ ជាសមិទ្ធផលថ្មីមួយទៀតនៃចក្ខុវិស័យពង្រីកវិសាលភាពប្រតិបត្តិការទូទាត់ឆ្លងដែនតាមយូអរកូតរបស់ប្រព័ន្ធបាគងឱ្យកាន់តែទូលំទូលាយ។ តាមរយៈក្របខណ្ឌកិច្ចសហប្រតិបត្តិការនេះ អតិថិជនរបស់ក្រុមហ៊ុនអន្តរជាតិយូញៀនផេ អាចស្កេនខេអេចយូអរកូត ដើម្បីទូទាត់ថ្លៃទំនិញ-សេវា ទៅឱ្យអាជីវករ ឬម្ចាស់ហាងលក់ទំនិញ-សេវានៅកម្ពុជា ដែលមានគណនីជាប្រាក់រៀលបាន។ ដូចគ្នានេះដែរ ចាប់ពីដើមឆ្នាំ២០២៤ តទៅ ប្រជាជនកម្ពុជាក៏អាចប្រើប្រាស់ប្រាក់រៀលក្នុងប្រព័ន្ធបាគង ឬកម្មវិធីធនាគារចល័ត ដើម្បីទូទាត់ថ្លៃទំនិញ-សេវា នៅក្នុងប្រទេសចិន និងបណ្តាប្រទេសផ្សេងៗទៀតក្នុងបណ្តាញទូទាត់ អន្តរជាតិយូញៀនផេ នៅទូទាំងពិភពលោកដោយគ្រាន់តែស្កេនយូអរកូតរបស់ក្រុមហ៊ុនអន្តរជាតិយូញៀនផេ (UnionPay QR Code)។



## ៥.២. ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន

ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់នាពេលបច្ចុប្បន្ន បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋកម្ពុជា ទាំងនីតិបុគ្គល និងរូបវន្តបុគ្គលលើការគ្រប់គ្រងលំហូរហិរញ្ញវត្ថុឆ្លងប្រទេសបានកាន់តែប្រសើរឡើងតាមប្រព័ន្ធធនាគារ ដើម្បីបម្រើដល់ការទូទាត់ពាណិជ្ជកម្មអន្តរជាតិ និងការផ្ទេរប្រាក់ឱ្យក្រុមគ្រួសារជាដើម។ ក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជាលើការត្រួតពិនិត្យគ្រឹះស្ថានដែលកំពុងផ្តល់សេវាទូទាត់សងប្រាក់ ការពិនិត្យនិងដាក់ចេញបទប្បញ្ញត្តិបន្ថែមសម្រាប់គ្រប់គ្រងហានិភ័យលើប្រព័ន្ធទូទាត់សងប្រាក់ រួមទាំងការពង្រីកវិសាលភាពនៃប្រព័ន្ធទូទាត់សងប្រាក់ បានធ្វើឱ្យប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាមានភាពរឹងមាំ និងគ្របដណ្តប់នៅទូទាំងប្រទេស ព្រមទាំងបានផ្តល់ការជឿទុកចិត្តនិងអត្ថប្រយោជន៍ជាច្រើនដល់អ្នកប្រើប្រាស់ រួមមាន កម្រៃសេវាសមរម្យ និងទទួលបានប្រាក់ភ្លាមៗ។

ក្នុងនាមជាអាជ្ញាធរ និងដើម្បីធានាឱ្យបាននូវភាពរឹងមាំនៃសេវាទូទាត់សងប្រាក់ឆ្លងដែន ធនាគារជាតិនៃកម្ពុជាបន្តយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តតាមរបស់គ្រឹះស្ថានឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិ និងបានធ្វើការតាមដានលើស្ថានភាពអាជីវកម្មរបស់គ្រឹះស្ថានជាប្រចាំ តាមរយៈការវិភាគលើរបាយការណ៍ដែលគ្រឹះស្ថានដាក់ជូនធនាគារជាតិនៃកម្ពុជា និងការចុះទៅត្រួតពិនិត្យដល់ទីតាំងរបស់គ្រឹះស្ថានផងដែរ។ លើសពីនេះ ដើម្បីផ្តល់ភាពងាយស្រួលលើការធ្វើប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជាក៏បានគាំទ្រដល់គ្រឹះស្ថានក្នុងការពង្រីកបណ្តាញសម្រាប់ផ្តល់សេវាទូទាត់សងប្រាក់ ហើយជាពិសេសជម្រុញការធ្វើប្រតិបត្តិការតាមបែបឌីជីថល ដោយអតិថិជនអាចស្នើធ្វើប្រតិបត្តិការផ្ទេរប្រាក់ពីគណនីរបស់ខ្លួនបានពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដែលបានចូលរួមចំណែកកាត់បន្ថយការចំណាយក្នុងការទៅធ្វើប្រតិបត្តិការដោយផ្ទាល់តាមសាខាធនាគារ និងជាពិសេសផ្តល់លទ្ធភាពឱ្យម្ចាស់អាជីវកម្ម អ្នកធុរកិច្ចសហគ្រាសខ្នាតតូចនិងមធ្យម អាចធ្វើការទូទាត់ទំនិញនៅក្រៅប្រទេសបានកាន់តែរហ័ស និងអាចគ្រប់គ្រងលំហូរសាច់ប្រាក់បានយ៉ាងងាយស្រួល។

បច្ចុប្បន្ន ចំនួនគ្រឹះស្ថានដែលមានផ្តល់សេវាផ្ទេរប្រាក់អន្តរជាតិបន្តកើនឡើងជាលំដាប់ ដោយក្នុងនោះមានគ្រឹះស្ថានប្រមាណ ២៧ កំពុងផ្តល់សេវាផ្ទេរប្រាក់ឆ្លងដែន ក្រោមកិច្ចសហការសាកល្បងជាមួយដៃគូជាក្រុមហ៊ុនផ្ទេរប្រាក់ក្រៅប្រទេស។ ជាទូទៅ គ្រឹះស្ថានដាក់ចេញកម្រៃសេវាដោយផ្អែកលើចន្លោះទំហំប្រាក់ផ្ទេរ ឬគិតក្នុងមួយប្រតិបត្តិការក្នុងតម្លៃជាក់លាក់ណាមួយ។ សម្រាប់កម្រៃសេវាផ្ទេរប្រាក់នៃកិច្ចសហការរវាងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងក្រុមហ៊ុនដៃគូផ្ទេរប្រាក់ក្រៅប្រទេសជាលក្ខណៈឯកជនទ្វេភាគី គិតជាមធ្យមស្ថិតក្នុងចន្លោះ ០,៦% ទៅ ៥,២% នៃទំហំប្រាក់ផ្ទេរក្នុងមួយប្រតិបត្តិការ ដោយពុំគិតលើថ្លៃសេវាផ្សេងៗទៀតនោះទេ។ ដោយឡែក សម្រាប់កម្រៃសេវាផ្ទេរប្រាក់តាមអ្នកដំណើរការតតិយភាគីគិតជាមធ្យមស្ថិតនៅចន្លោះ ០,៣៩% ទៅ ៣% ឬក៏រួមទាំងតម្លៃ Cable Charge បន្ថែម ជាមធ្យមដោយអាស្រ័យលើប្រទេសគោលដៅ ៥០ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ។

រីឯកម្រៃសេវាផ្ទេរប្រាក់តាមប្រព័ន្ធស្វីស នៅរក្សាតម្លៃ ០,១៥% នៃទំហំប្រាក់ប្រតិបត្តិការ និងបូកបន្ថែមតម្លៃ Cable Charge ១៥ ដុល្លារអាមេរិក (តាមការកំណត់របស់ធនាគារភាគច្រើន)។

ក្នុងឆ្នាំ២០២៣ ចំនួនប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អ្នកដំណើរការតតិយភាគី និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មានចំនួនប្រមាណ ៣,៧៨ លានប្រតិបត្តិការ (កើនឡើង ១៥,៨%) និងទំហំប្រាក់មានចំនួនប្រមាណ ៦៤,៦១ ប៊ីលានដុល្លារអាមេរិក (កើនឡើង ០,០២%) ស្មើនឹង ២០១,១% នៃផ.ស.ស។ ការទូទាត់ទំនិញនិងសេវាផ្ទេរប្រាក់ឆ្លងដែននៅបន្តឆ្លងកាត់ប្រព័ន្ធស្វីសជាចម្បងដោយសារប្រព័ន្ធនេះផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់អាចទូទាត់បានក្នុងទំហំប្រាក់ធំ មានបណ្តាញទូលំទូលាយលើសកលលោក និងមានសុវត្ថិភាពខ្ពស់។ បន្ទាប់ពីប្រព័ន្ធនេះ មានគ្រឹះស្ថានមួយចំនួនតូចកំពុងអនុវត្ត និងរៀបចំដាក់ឱ្យដំណើរការសាកល្បងនូវសេវាផ្ទេរប្រាក់អន្តរជាតិផ្សេងទៀត មានដូចជាការតភ្ជាប់ប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ វីសា (VISA) ជាដើម ដើម្បីធ្វើប្រតិបត្តិការបានរហ័សជាងមុន និងមានកម្រៃទាបជាងមុន។ ជាទូទៅ ទំហំប្រាក់សរុបនៃការផ្ទេរចេញតាមប្រព័ន្ធខាងលើនេះនៅរក្សាចំនួនធំជាងការផ្ទេរចូល ដោយអាស្រ័យលើកត្តាសកម្មភាពសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន។ ចំណែកឯ សេវាផ្ទេរប្រាក់តាមរយៈក្រុមហ៊ុនផ្តល់សេវាផ្ទេរប្រាក់ឆ្លងដែននៅក្រៅប្រទេស នៅបន្តទទួលបានការគាំទ្រខ្ពស់លើការផ្ទេរប្រាក់ឱ្យក្រុមគ្រួសារ និងសម្រាប់ការទូទាត់អាជីវកម្មខ្នាតតូចនិងមធ្យម ដោយសារសេវានេះមានកម្រៃសេវាទាប ដែលនាំឱ្យទំហំប្រតិបត្តិការតាមសេវានេះមានការកើនឡើងច្រើន និងមានទំហំប្រាក់ផ្ទេរចូលច្រើនជាងការផ្ទេរចេញ។

**ក្រាហ្វ ២០ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចាប់តាំងពីឆ្នាំ២០០៣ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការនូវប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (International Transactions Reporting System - ITRS) ក្នុងគោលបំណងផ្តល់ភាពងាយស្រួល និងជាមធ្យោបាយដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់រាយការណ៍អំពីការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន។ បច្ចុប្បន្ន មានគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន ៦១ កំពុងរាយការណ៍តាមរយៈប្រព័ន្ធ ITRS នេះ។ ការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន ជាការផ្ទេរប្រាក់ផ្លូវការបែបអេឡិចត្រូនិកចម្បងមួយ តាមរយៈប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ហើយការផ្ទេរប្រាក់នេះភាគច្រើនធ្វើឡើងដោយពលករចំណាកស្រុកនៅក្រៅប្រទេស។ ក្នុងឆ្នាំ២០២៣ ពលករចំណាកស្រុកបានផ្ទេរប្រាក់មកក្រុមគ្រួសារពីប្រទេសកូរ៉េខាងត្បូងប្រមាណ ៥៣,៥% នៃទំហំប្រាក់ផ្ទេរឆ្លងដែនជាលក្ខណៈឯកជនសរុប ហើយសហរដ្ឋអាមេរិកចំនួន ១៨,២% និងបន្តដោយប្រទេសជប៉ុន ៦,៦% និងប្រទេសអូស្ត្រាលី ៣,៦%។ ធនាគារជាតិនៃកម្ពុជាដែលជាបញ្ញត្តិករ និងអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឬផលិតផលថ្មីៗប្រកបដោយនវានុវត្តន៍ ដើម្បីលើកកម្ពស់ដល់ការប្រកួតប្រជែង ក៏ដូចជារួមចំណែកធ្វើឱ្យការផ្តល់សេវាផ្ទេរប្រាក់កាន់តែមានតម្លៃទាប ងាយស្រួល ឆាប់រហ័ស និងមានតម្លាភាពសម្រាប់អតិថិជន។ សរុបមក ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឬផលិតផលថ្មីៗទាំងនេះ ជាកត្តាដ៏សំខាន់ក្នុងការលើកទឹកចិត្តឱ្យសាធារណជនងាកមកប្រើប្រាស់សេវាផ្ទេរប្រាក់តាមរយៈបណ្តាញផ្លូវការវិញ។

**ក្រាហ្វ ២១ - ទំហំប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន តាមប្រព័ន្ធ ITRS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១ - ច្បាប់ និងបទប្បញ្ញត្តិ

| ល.រ. | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
|---|---|---|
| ១ | ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារនៃកម្ពុជា | ១៩៩៦ |
| ២ | ច្បាប់ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ | ១៩៩៧ |
| ៣ | ច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ | ១៩៩៩ |
| ៤ | ច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០០៥ |
| ៥ | ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | ២០២០ |
| ៦ | ច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | ២០២០ |
| ៧ | ប្រកាសស្តីពី ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ | ២០០៦ |
| ៨ | ប្រកាសស្តីពី ប្រតិបត្តិការនៃគណនីទូទាត់ | ២០០៦ |
| ៩ | ប្រកាសស្តីពី មូលប្បទានបត្រស្តង់ដារ | ២០០៨ |
| ១០ | ប្រកាសស្តីពី ការកំណត់លេខអត្តសញ្ញាណធនាគារ | ២០០៨ |
| ១១ | ប្រកាសស្តីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន | ២០១០ |
| ១២ | ប្រកាសស្តីពី អ្នកដំណើរការតតិយភាគី | ២០១០ |
| ១៣ | ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ | ២០១៤ |
| ១៤ | ប្រកាសស្តីពី សមាជិកភាពនៃប្រព័ន្ធសេវាទូទាត់រហ័ស និងប្រព័ន្ធខេមបូខានស៊ែស្វីច | ២០១៦ |
| ១៥ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ | ២០១៦ |
| ១៦ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធីប្រព័ន្ធខេមបូខានស៊ែស្វីច | ២០១៧ |
| ១៧ | ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៧ |
| ១៨ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស និងប្រព័ន្ធខេមបូខានស៊ែស្វីច | ២០១៨ |

| លរ. | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
|---|---|---|
| ១៩ | ប្រកាសស្ដីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធរីផែលផេ | ២០១៩ |
| ២០ | ប្រកាសស្ដីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធីប្រព័ន្ធរីផែលផេ | ២០២០ |
| ២១ | ប្រកាសស្ដីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេស ខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់ | ២០២០ |
| ២២ | ប្រកាសស្ដីពី ការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធបាគង | ២០២០ |
| ២៣ | ប្រកាសស្ដីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង | ២០២០ |
| ២៤ | ក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ | ២០២០ |
| ២៥ | សារាចរណែនាំស្ដីពី ការពង្រឹងការអនុវត្តច្បាប់ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០១៦ |
| ២៦ | សារាចរណែនាំស្ដីពី នីតិវិធីស្គាល់អត្តសញ្ញាណអតិថិជន និងការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា | ២០២១ |
| ២៧ | សេចក្ដីជូនដំណឹងស្ដីពី កម្រៃប្រតិបត្តិការផ្ទេរប្រាក់សម្រាប់ "សេវាទូទាត់រហ័ស" | ២០១៧ |
| ២៨ | សេចក្ដីជូនដំណឹងស្ដីពី កម្រៃ សោហ៊ុយ និងការពិន័យសម្រាប់ប្រព័ន្ធខេមបូខានស៊ែស្វីច | ២០១៧ |
| ២៩ | សេចក្ដីជូនដំណឹងស្ដីពី ការកែសម្រួលគោលនយោបាយសមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិ របស់សភាផាត់ទាត់ជាតិ | ២០១៨ |
| ៣០ | សេចក្ដីជូនដំណឹងស្ដីពី គោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកមិនផ្ទាល់ និងកិច្ចសហការរវាងសមាជិកផ្ទាល់និងសមាជិកមិនផ្ទាល់ក្នុងប្រព័ន្ធផាត់ទាត់ជាតិ | ២០១៩ |
| ៣១ | សេចក្ដីជូនដំណឹងស្ដីពី ការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធខេមបូខានស៊ែស្វីច | ២០២០ |
| ៣២ | សេចក្ដីជូនដំណឹងស្ដីពី គោលនយោបាយពាក់ព័ន្ធនឹងសមាជិកភាពប្រព័ន្ធខេមបូខាន-ស៊ែស្វីច | ២០២០ |
| ៣៣ | សេចក្ដីណែនាំស្ដីពី កាលបរិច្ឆេទ និងរយៈពេលសម្រាប់ការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ៣៤ | សេចក្ដីណែនាំស្ដីពី ការជ្រើសរើស និងការទទួលស្គាល់ស្នងការគណនេយ្យឯករាជ្យចំពោះគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ៣៥ | ឯកសារបាគង White Paper | ២០២០ |
| ៣៦ | សេចក្ដីណែនាំស្ដីពី "ការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់កិច្ចសហការផ្ទេរប្រាក់អន្តរជាតិ ក្នុងដំណាក់កាលសាកល្បង" | ២០២៣ |

## ឧបសម្ព័ន្ធ ២ - បញ្ជីរាយនាមឈ្មោះសមាជិកប្រព័ន្ធបាគង

| ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការប្រព័ន្ធបាគង | ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការប្រព័ន្ធបាគង |
|---|---|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២១ | ធនាគារ អេស បី អាយ លីហួរ ម.ក |
| ២ | ធនាគារ វីង (ខេមបូឌា) ម.ក | ២២ | ធនាគារ បី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ២៣ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក |
| ៤ | ធនាគារ វឌ្ឍនៈ | ២៤ | ធនាគារ អូរៀនថល ម.ក |
| ៥ | ធនាគារ ស្ថាបនា ភីអិលស៊ី | ២៥ | ធនាគារ ហុងលីអុង (ខេមបូឌា) ភីអិលស៊ី |
| ៦ | ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ | ២៦ | ធនាគារ អ អេច បី (ខេមបូឌា) ម.ក |
| ៧ | ធនាគារ ព្រីនស៍ ម.ក | ២៧ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ |
| ៨ | ធនាគារ កាណាឌីយ៉ា ក.អ | ២៨ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៩ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៩ | សាជីវកម្មធនាគារ កាថេយូណៃធីតកម្ពុជា ចំកាត់ |
| ១០ | ធនាគារ ភ្នំពេញពាណិជ្ជ ម.ក | ៣០ | ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ១១ | ធនាគារ វិនិយោគ និងអភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី | ៣១ | ធនាគារ អាយ ស៊ី បី ស៊ី សាខាភ្នំពេញ |
| ១២ | ធនាគារ ហ្វីលីព ភីអិលស៊ី | ៣២ | ធនាគារ ស៊ី អាយ អិម បី ភីអិលស៊ី |
| ១៣ | ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ | ៣៣ | ធនាគារ ពាណិជ្ជទីមួយ សាខាភ្នំពេញ |
| ១៤ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ៣៤ | ធនាគារ សាខម ប៊ែង ខេមបូឌា |
| ១៥ | ធនាគារ ហត្ថា ម.ក | ៣៥ | ធនាគារ ហោង ហ្វឹង (ខេមបូឌា) ម.ក |
| ១៦ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ៣៦ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក |
| ១៧ | ធនាគារ មេយប៊ែង (ខេមបូឌា) ម.ក | ៣៧ | ធនាគារ ផេនដា ខមមើសល ប៊ែង ម.ក |
| ១៨ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក | ៣៨ | ធនាគារ អឹម បី (ខេមបូឌា) ម.ក |
| ១៩ | ធនាគារ តូកមីន កម្ពុជា ភីអិលស៊ី | ៣៩ | ធនាគារ សហពាណិជ្ជ ក.អ |
| ២០ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ៤០ | ធនាគារ ឌីជីបី ម.ក |

| ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការប្រព័ន្ធបាគង | ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការប្រព័ន្ធបាគង |
|---|---|---|---|
| ៤១ | ធនាគារ ប្រ៊ីដ ម.ក | ៥០ | គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិុន សឹលូសិន ម.ក |
| ៤២ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក | ៥១ | គ្រឹះស្ថាន លីហ្សូរ ផេប្រ៊ូ ភីអិលស៊ី |
| ៤៣ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ប្រាសាក់ ម.ក | ៥២ | គ្រឹះស្ថាន អាយផេ88 (ខេមបូឌា) ម.ក |
| ៤៤ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អេ អឹម ខេ ភីអិលស៊ី | ៥៣ | គ្រឹះស្ថានផានស៊ូ អ៊ិនផើណេសិនណលថេកណូឡូជី ម.ក |
| ៤៥ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី | ៥៤ | គ្រឹះស្ថាន អេស៊ា ឃែស អិចប្រេស ម.ក |
| ៤៦ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អម្រឹត ម.ក | ៥៥ | គ្រឹះស្ថាន ផាយ ផេ ម.ក |
| ៤៧ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មហានគរ ម.ក | ៥៦ | គ្រឹះស្ថាន បងឡូយ ផេមិុន ម.ក |
| ៤៨ | គ្រឹះស្ថាន ស្ពីត ផេ ម.ក | ៥៧ | គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក |
| ៤៩ | គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក | ៥៨ | គ្រឹះស្ថាន ឡានតុន អ៊ិនធើណេសិនណល (ខេមបូឌា) ផេមិុន សឺវីស ម.ក |

# ឧបសម្ព័ន្ធ ៣ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

**គ្រឹះស្ថាន អ៊ីឌាល (ខេមបូឌា) ម.ក**
អាគារលេខ ១៥ ផ្លូវលេខ ៣៩៧ ភូមិ៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
០៩៦ ៩៦៦ ៣៣៣៣ / ០៩៦ ៨១៥ ៧៣៨៨
www.edeel.com

**គ្រឹះស្ថាន ស៊ីធែល ហ្វាយនែនសល សឺវីស ម.ក**
អាគារលេខ១៩៩ ផ្លូវលេខ៤៣២ ភូមិ៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
០១៨ ៨៨០០ ៨០០
www.bestmpay.com

**គ្រឹះស្ថាន យូប៊ីល ម.ក**
អាគារលេខ B3&C3-1 ផ្លូវ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០៣៨ ៣៣០០ ៨៨៨
www.coobill.com.kh

**គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក**
អាគារ Keystone (No.146) ជាន់ទី១-២-៤ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៩៩ ៦៣៩
www.truemoney.com.kh

**គ្រឹះស្ថាន លី ហួរ ផេ ប្រ៉ូ ភីអិលស៊ី**
ដីឡូតិ៍ ២៤៣-២៤៤ ការិយាល័យ (១៥C - ៤១C) ផ្លូវ ៥៩៨ សង្កាត់ទួលសង្កែទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
០៨៧ ៦០១ ១១១
www.lyhourpay.com

**គ្រឹះស្ថាន ស្ពីត ផេ ម.ក**
ផ្ទះលេខ B48, B49 ផ្លូវបុរីឡាសែន ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៧០ ៩៩៧ ៧៧៥
www.speedpayplc.com

**គ្រឹះស្ថាន អាប៊ីត្រេរី ផេយ ម.ក**
Mei Lian Garden Hotel លេខ៣១៥ វិឡាលេខ១១៣ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
០១០ ៣៧០ ៨៨៨

**គ្រឹះស្ថាន អាយផេ៨៨ (ខេមបូឌា) ម.ក**
ផ្ទះលេខ១៣ (ជាន់ទី២) មហាវិថីហ្សាលដឺហ្គោល (២១៧) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០២៣ ៩០១ ៧៨៨
www.ipay88.com.kh

**គ្រឹះស្ថាន ផាយ ផេ ម.ក**
ផ្ទះលេខ២០ ផ្លូវ ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០២៣ ៩៨៨ ៩៨៩
www.pipay.com

**គ្រឹះស្ថាន ធានស៊ូ អ៊ិនធើណេសិនណល ថេកណូឡូជី ម.ក**
អគារលេខ ៤៨-៥០ ជាន់ទី៣ ផ្លូវ ៣១០ ភូមិ ២ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០២៣ ៩៨៨ ៧៧៧
www.coolcashcam.com

**គ្រឹះស្ថាន បងឡូយ ផេមិន ម.ក**
ផ្ទះលេខ ៨៧ ផ្លូវ ៦៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០៨១ ៩៩៩ ៦១៨
www.bongloy.asia

**គ្រឹះស្ថាន អេស៊ា វៃលុយ អិចប្រេស ម.ក**
ផ្ទះលេខ B២-០៣៥-០៣៦ ផ្លូវកោះពេជ្រ (ស្ពានឥន្ទនូ) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៨ ៦៦៦ ៦៧៨ / ០៩៩ ៦៦៦ ៦៧៨ / ០៧១ ៦៦៦ ៦៧៨
www.asiaweiluy.com.kh

**គ្រឹះស្ថាន ហួយវ៉ន ផេ ម.ក**
អាគារលេខ ៦២ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០២៣ ២៣១ ៩៩៩
www.7572.com

**គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិន សឹលូសិន ម.ក**
អគារលេខ២៣៤ (ROYAL K PLAZA) ជាន់ទី១៥ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០៧១ ៦៥៥ ៥៦៦៦
www.emoney.com.kh

**គ្រឹះស្ថាន ដ្រេហ្គនហ្វ្លាយ ហ្វីនថេក (ខេមបូឌា) ម.ក**
អាគារ ROSE GARDEN លេខ២៥២ ជាន់ផ្ទាល់ដី សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៨ ២១៨ ៥៥៥
www.dragonfly.com.kh

### គ្រឹះស្ថាន ដាយនៃមីក ផេមិុន ម.ក

អគារម៉េរហ្វែន ជាន់ទី៦ បន្ទប់លេខ០២ និង០៣ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៨៩ ១៨៦ / dpkh@dynamicg.com

### គ្រឹះស្ថាន តារាសាគរ ផេ ម.ក

ប្លុក៧៣ ជាន់ផ្ទាល់ដី អគារលេខ២ Phnom Penh City Center ផ្លូវ៦១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០៩៣ ៩៣៩ ៩៧៧
www.darasakorpay.com

### គ្រឹះស្ថាន បៃ សេន ថេកណូឡូជី ម.ក

Elite Town លេខ ០៥ ផ្លូវ Stanford សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៧១ ៩៩៩ ៧៧៧៩

### គ្រឹះស្ថាន អ៊ែរទ្រីណូ គ្លូបល ម.ក

ផ្ទះលេខ៥៤B (ជាន់ផ្ទាល់ដី និងជាន់ទី១) ផ្លូវ ៩៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៦ ៩៥៥ ៥៥៥៦

### គ្រឹះស្ថាន ផារ៉ាហ្គុន ផេមិុន សឺវីស ម.ក

អាគារលេខ២១៦ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០១២ ៤៥៦ ២៣៧

### គ្រឹះស្ថាន ឃេស អ៊ិននើវេសិន ម.ក

អាគារលេខ១០៥ ជាន់ទី៤ ផ្លូវ ១៩៨៤A សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
០៧០ ២២២ ៧០៣
www.kessinnovation.io

### គ្រឹះស្ថាន អិលអិម ផេ ម.ក

អាគារលេខ ៦៣៥ ជាន់ទី២ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០១០ ៨០០ ៦០២ / ០១០ ៥៣៣ ៨៨៨
www.lmpay.com

**គ្រឹះស្ថាន តាំង គួង ផេ ម.ក**
ផ្ទះលេខអេ១១ ផ្លូវលេខ២១០ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
០៩៩ ២៣៣ ២៣៣
www.tangkungpay.com

**គ្រឹះស្ថាន លីន ផេ ផេមិុន សឹលូសិន ម.ក**
ផ្ទះលេខ ៩០ ៩២ និង៩៤ ជាន់ទី១ (E-1) ផ្លូវលេខ ២១៧ សង្កាត់អូឬស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០៩៦ ៦៧៥ ៣៥៥៤
www.lync-pay.com

**គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក**
អាគារលេខ១ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៨១ ៩៧៨ ៨៨៩ / ០៨៥ ៩៧៨ ៨៨៩
www.u-pay.com

**គ្រឹះស្ថាន ស្កាយផេ ហ្វីនថេក ម.ក**
ដីឡូត៍លេខ២៧៨៧ ភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល
០៨១ ៩១៦ ១០៩

**គ្រឹះស្ថាន ឡានតុន អិនធើណេសិនណល (ខេមបូឌា) ផេមិុន សឺវីស ម.ក**
California Social House (West) លេខ ៥៧១-៥៧៥ D&E ជាន់ទី២ បន្ទប់លេខ០២
មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
០២៣ ៩០០ ០៩១ / ០២៣ ៩០០ ០៩១
www.lantonpay.com

**គ្រឹះស្ថាន វីង ម៉ាន់នី (ខេមបូឌា) ម.ក**
ផ្ទះលេខ ៧២១ មហាវិថីព្រះមុន្នីវង្ស ភូមិ ៩ សង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

**គ្រឹះស្ថាន ឌ្លីក ផេមិុន (ខេមបូឌា) ម.ក**
DK Santuary លេខ ១២៨ EF ជាន់ទី៤ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០១០ ៩២៧ ៩៥០

**គ្រឹះស្ថាន សាន់ផេ (ខេមបូឌា) ម.ក**
អាគារ Morgan Tower, Unit 7/8a/8b, ជាន់ទី២០ ផ្លូវសុភមង្គល (កោះពេជ្រ) ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៦ ៦៧៨ ២៦៧៨

**គ្រឹះស្ថាន កៃ ហ្វូ តុង ផេមិន ម.ក**
សណ្ឋាគារប្លាទីនអន្តរជាតិ ផ្លូវប៉ូឡូវែជាន់ទី ១ និងទី២ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
០៩៣ ៩២២ ២២៩
www.cpay168.com

**គ្រឹះស្ថាន ផេយ៉ុន ម.ក**
លេខ ៣F មជ្ឈមណ្ឌល PGCT ផ្លូវលេខ ២៧៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៨៧ ៩៧៥
www.payon.com.kh

**គ្រឹះស្ថាន ជីន ហុង ជិន ថេកណូឡូជី ម.ក**
ផ្ទះលេខ ៣៨ ផ្លូវលេខ ៤៦៨ ភូមិ១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៨៨ ៣២៣ ១១៨៨៨
www.dvpay.com

# ឧបសម្ព័ន្ធ ៤ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក

## ១. គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត

| ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត | ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | ២១ | ធនាគារ មីហ្សូហូ អិលធីឌី |
| ២ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២២ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៣ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | ២៣ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក |
| ៤ | ធនាគារ ចិន | ២៤ | ធនាគារ ហ្វីលីព ភីអិលស៊ី |
| ៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | ២៥ | ធនាគារ ព្រីនស៍ ម.ក |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២៦ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៧ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | ២៧ | ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៨ | ធនាគារ ស្ថាបនា ភីអិលស៊ី |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ២៩ | ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ៣០ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ១១ | សាជីវកម្មធនាគារ កាថេ យូណៃធីត (កម្ពុជា) ចំកាត់ | ៣១ | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ |
| ១២ | ធនាគារ ពាណិជ្ជទីមួយ | ៣២ | ធនាគារ សហពាណិជ្ជ ក.អ |
| ១៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៣៣ | ធនាគារ វឌ្ឍនៈ |
| ១៤ | ធនាគារ ហត្ថា ម.ក | ៣៤ | ធនាគារ ឌីជីប៊ី ម.ក |
| ១៥ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | ៣៥ | សាខាធនាគារកសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) |
| ១៦ | សាខាធនាគារ អ៊ិនដាសស្មៀល ប៊ែង អហ្វ ខូរៀ ភ្នំពេញ | ៣៦ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ១៧ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | ៣៧ | ធនាគារ អូរៀនថល ម.ក |
| ១៨ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | ៣៨ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក |
| ១៩ | ធនាគារ ខេប៊ី ប្រាសាក់ ម.ក | | |
| ២០ | ធនាគារ មេហ្គា អ៊ីនធើណេសិនណល ខមមើសល ប៊ែង ខូអិលធីឌី សាខាភ្នំពេញ | | |

## ២. គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត

| ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត | ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | ២០ | ធនាគារ អ អេច បី (ខេមបូឌា) ម.ក |
| ២ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | ២១ | ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៣ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី | ២២ | ធនាគារ ស្ថាបនា ភីអិលស៊ី |
| ៤ | ធនាគារ ចិន | ២៣ | ធនាគារ អេស ប៊ី អាយ លីហ្សរ ម.ក |
| ៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | ២៤ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២៥ | ធនាគារ សហពាណិជ្ជ ក.អ |
| ៧ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ២៦ | ធនាគារ វឌ្ឍនៈ |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៧ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ២៨ | ធនាគារ ឌីជីប៊ី ម.ក |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ២៩ | ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី |
| ១១ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៣០ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ១២ | ធនាគារ ហត្ថា ម.ក | ៣១ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក |
| ១៣ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | ៣២ | ធនាគារ អូរៀនថល ម.ក |
| ១៤ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | ៣៣ | ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ១៥ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | ៣៤ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក |
| ១៦ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក | ៣៥ | ធនាគារ ហេង ហ្វឹង (ខេមបូឌា) ម.ក |
| ១៧ | ធនាគារ ហ្វីលីព ភីអិលស៊ី | ៣៦ | ធនាគារ អ៊ឹមប៊ី (ខេមបូឌា) ម.ក |
| ១៨ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | ៣៧ | ធនាគារ ខេប៊ី ប្រាសាក់ ម.ក |
| ១៩ | ធនាគារ ព្រីនស៍ ម.ក | | |

# ឧបសម្ព័ន្ធ ៥ - ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបាគង

១. ប្រព័ន្ធបាគងមានលក្ខណៈជាប្រព័ន្ធទូទាត់សងប្រាក់កន្លោង



## ២. ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបាគង





KHQR